ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា (នីតិកាលទី៣)
គណៈកម្មការនីតិកម្ម និងយុត្តិធម៌

# ឯកសារជំនួយស្មារតី
# ស្តីពី
# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
# នៅឃុំ សង្កាត់

(ខែមីនា ឆ្នាំ២០១៧)

រៀបចំ និងចងក្រងដោយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា និងលេខាធិការដ្ឋានអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

# អារម្ភកថា

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា តែងមានកម្មវិធីជាប្រចាំចុះបំពេញបេសកកម្មការងារតាមបណ្តាមូលដ្ឋាន ដើម្បីធ្វើការសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ទាំងឡាយដែលបានចូលជាធរមាន ជាពិសេសអំពីពល់បញ្ហាដែលទាក់ទង និងវិស័យជាសមត្ថកិច្ចរបស់ខ្លួន។

យើងសង្កេតឃើញថាក្នុងចំណោមប្រជាជនយើងដែលភាគច្រើនជាអ្នករស់នៅទីជនបទជារឿយៗតែងតែកើតមាននូវជម្លោះដែលភាគច្រើនជាជម្លោះរវាងបុគ្គល និងបុគ្គលក្នុងវង្សត្រកូល និងជម្លោះត្រកូលមួយនឹងត្រកូលផ្សេងទៀត។ បញ្ហាអំពើហិង្សាក្នុងគ្រួសារ ហិង្សាលើស្ត្រី បញ្ហាដីធ្លី រឿងកិច្ចសន្យា និងរឿងព្រហ្មទណ្ឌតូចតាចតែងកើតមានឡើងច្រើនជាងគេក្នុងចំណោមជម្លោះទាំងឡាយ។

ម្យ៉ាងវិញទៀតស្ថាប័នតុលាការនៅមិនទាន់អាចដោះស្រាយគ្រប់ជម្លោះដែលបានកើតឡើងទាំងអស់នោះទេ។ ប្រជាជននៅជនបទយល់ឃើញថាការធ្វើដំណើរទៅតុលាការមានចម្ងាយឆ្ងាយគាត់ត្រូវការចំណាយថវិកាច្រើនហើយម្យ៉ាងទៀតនៅតុលាការក៏មានសំណុំរឿងច្រើនផងដែរ។

រយៈកាលកន្លងមករាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវកំណែទម្រង់ប្រព័ន្ធតុលាការដោយបង្កើតនូវស្ថាប័នមានសមត្ថកិច្ចជាច្រើន : ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋឆ្នាំ១៩៩៩ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងឆ្នាំ២០០២ ហើយគណៈរដ្ឋមន្ត្រី ក៏បានធ្វើការអនុម័តទៅលើយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅក្នុងឆ្នាំ២០០៣ និងផែនការសកម្មភាពក្នុងឆ្នាំ២០០៥។

គោលបំណងនៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌ និងតុលាការគឺជាការបង្កើតនូវស្ថាប័នដែលមានកិត្យានុភាព និងស្ថិរភាពច្បាប់ និងយុត្តិធម៌ប្រកាន់ខ្ជាប់នូវគោលការណ៍ សិទ្ធិបុគ្គលនីតិរដ្ឋ និងភាពបែកដាច់ពីគ្នានៃអំណាចក្នុងប្រព័ន្ធប្រជាធិបតេយ្យ។ ដើម្បីទទួលបាននូវភាពជោគជ័យ ក្នុងការអនុវត្តគោលបំណងនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវគោលដៅយុទ្ធសាស្ត្រប្រាំពីរចំណុចដែលក្នុងនោះ គឺគោលដៅទីប្រាំមួយបានណែនាំនូវយុទ្ធសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ចំណែកឯផែនការសកម្មភាពដែលមាន

គោលបំណងបង្កើតស៊ើបអង្កេត និងពង្រឹងនូវវិធីសាស្ត្រផ្សេងៗនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានយកចិត្តទុកដាក់ជាពិសេសតាំងពីនៅថ្នាក់ឃុំ ស្រុក ខេត្ត រហូតដល់ថ្នាក់ជាតិ ។

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា រៀបរៀងឯកសារជំនួយស្មារតីនេះឡើងដែលបានដកស្រង់នូវខ្លឹមសារសំខាន់ៗពីបទដ្ឋានគតិយុត្តមួយចំនួនដែលបានចូលជាធរមានសម្រាប់ដល់ការស្រាវជ្រាវ និងប្រើប្រាស់របស់អាជ្ញាធរដែលមានសមត្ថកិច្ចៗវាអាចបានរួមចំណែកជាសំខាន់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាពិសេសគឺ គណៈកម្មការផ្សះផ្សាទំនាស់ឃុំសង្កាត់ មណ្ឌលសេវាកម្មយុត្តិធម៌ និងគណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ ក្នុងដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការកាន់តែទទួលបាននូវជោគជ័យ និងបានរួមចំណែកពង្រឹងប្រព័ន្ធយុត្តិធម៌សង្គមនៅកម្ពុជាយើងៗ

# មាតិកា


I-គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់......................................០៤

II-អំពីមាត្រាមួយចំនួននៃច្បាប់ និងប្រការទាំងឡាយនៃលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយទំនាស់នៅឃុំ សង្កាត់ ដែលគួរយល់ដឹង ៖......................................១០

+អំពីអំពើហិង្សាក្នុងគ្រួសារ......................................១០

+អំពីអាពាហ៍ពិពាហ៍......................................១៣

+អំពីការលែងលះ......................................២៤

+.អំពីការផ្តាច់ពាក្យរៀបការ......................................២៧

+.អំពីទ្រព្យសម្បត្តិ......................................២៧

+អំពីដីធ្លី......................................៣០

+.អំពីបរិហារកេរ្តិ៍ជាសាធារណៈឬជេរប្រមាថ......................................៣៦

+.អំពីការជំពាក់ប្រាក់និងកិច្ចសន្យា......................................៣៧

+.អំពីការបង្កការខូចខាតទ្រព្យសម្បត្តិ......................................៤៦

+.អំពីការបង្ករបួសស្នាមតូចតាច......................................៤៧

III-អត្រានុក្កូលដ្ឋាន......................................៤៨

IV-គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព......................................៥៩

V-តួនាទីភារកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់......................................៦៤

VI-ប្រជាការពារ......................................៦៧

VII-សៀវភៅស្នាក់នៅ......................................៧១

VIII-បែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ......... ......................៧៣

IX-នីតិវិធី លក្ខខណ្ឌ នៃការសុំការផ្តល់និងការប្រើប្រាស់អត្តសញ្ញាណ - - បណ្ណ័សញ្ជាតិខ្មែរ......................................៧៥

X-ការផ្តល់សេវារដ្ឋបាល......................................៨២

## I. គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់[1]

-គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ គឺជាគណៈកម្មាធិការដែលបង្កើតឡើងដោយឃុំ សង្កាត់ ដើម្បីជួយឃុំ សង្កាត់ក្នុងការផ្សះផ្សាវិវាទ។ សិទ្ធិនៅក្នុងការបង្កើតនេះមានចែងនៅក្នុងមាត្រា២៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា៖ «ឃុំចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់និងជួយកិច្ចការនានាតាមការចាំបាច់។ គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំសង្កាត់ឲ្យធ្វើជាប្រធានក៏បានឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឲ្យធ្វើជាប្រធានក៏បាន»។

+<u>ទិសដៅរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មានដូចតទៅ</u>[2]៖

(យោងសៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ ចុះហត្ថលេខាដោយក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០)

-កាត់បន្ថយស្ថានភាពទំនាស់ និងគ្រប់គ្រងទំនាស់ដែលកើតមាននៅតាមមូលដ្ឋាន។

-ធ្វើការសម្រុះសម្រួលទំនាស់ក្នុងករណីមានការព្រមព្រៀងពីភាគីទំនាស់។

-ផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ដែលចាំបាច់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

-ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងចង្អុលបង្ហាញនីតិវិធីបន្តដល់ភាគីទំនាស់ក្នុងករណីទំនាស់មិនអាចដោះស្រាយបាន ឬភាគីទំនាស់មិនមានបំណងដោះស្រាយជួយសម្រួលដល់ការងារដោះស្រាយទំនាស់របស់ឃុំសង្កាត់នៅថ្នាក់មូលដ្ឋាន។

+<u>តួនាទីរបស់គណៈកម្មាធិការមានដូចតទៅ</u>[3] ៖

-គ្រប់គ្រង និងកាត់បន្ថយជម្លោះមូលដ្ឋាន

-សន្ទានកម្ម និងផ្សះផ្សាជម្លោះប្រសិនបើភាគីយល់ព្រម

-ចែកចាយព័ត៌មានផ្នែកច្បាប់ទៅមូលដ្ឋាន

-ជួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ

---

[1] ឯកសារស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ PIC ទំព័រទី១១

[2] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី១

[3] ឯកសារស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ PIC ទំព័រទី១២

+<u>តួនាទីនិងភារកិច្ចរបស់សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់</u>[4]

-សម្រុះសម្រួលរាល់វិវាទរដ្ឋប្បវេណី តាមគោលការណ៍ស្ម័គ្រចិត្តរបស់គូភាគី

-សម្រុះសម្រួលបទលហុតាមគោលការណ៍ស្ម័គ្រចិត្តរបស់គូភាគី

-ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ

-ជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការពង្រឹងសមត្ថភាពការដោះស្រាយទំនាស់នៅថ្នាក់ភូមិ

-ជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការរៀបចំនិងបង្កើតក្រុមដោះស្រាយទំនាស់នៅភូមិ

+<u>គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ មានសមាជិកចំនួន០៧រូប</u>[5] ៖

| | |
|---|---|
| -សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ១រូបជាប្រធាន |
| - ជនបង្គោលនារីឃុំ | ១រូបជាអនុប្រធាន |
| -ប្រធានឬអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ | ១រូប ជាសមាជិក |
| -ប្រជាជនដែលមានកិត្តិយសនិងការគោរពរាប់អាន | |
| -ឬមានឥទ្ធិពលក្នុងឃុំ សង្កាត់ | ៤រូបជាសមាជិក។ |

+<u>មាត្រា ៤៣</u> (នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១) បានចែងថា

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចៈ

-ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

-រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ

-លើកទឹកចិត្តឲ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

-ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

-ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

-សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

-បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

---

[4] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី២

[5] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី១

**+.អនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់** *លេខ២២ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦*

**-ជំពូកទី៣ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់**

+មាត្រា៣១ នៃ(អនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ លេខ២២ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦) បានចែងថា ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើឬធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវឆ្លើយតបនឹងសំណើឬការប្តឹងតវ៉ានោះជាកំហិត។

ចំពោះសំណើ ឬការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់អាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដោះស្រាយ ហើយចាត់អោយជូនព័ត៌មានអំពីការដោះស្រាយនោះដល់ប្រជាពលរដ្ឋវិញ រួចហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំបន្ទាប់។

ចំពោះសំណើឬការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់មិនអាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ ត្រូវដាក់ក្នុងរបៀបវារៈអង្គប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

+មាត្រា៣២ នៃ(អនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ លេខ២២ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦) បានចែងថា ចំពោះសំណើឬការប្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័នឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលមានសមត្ថកិច្ច។

+មាត្រា៤៤ (នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១) បានចែងថា .

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម:

-ព្រៃឈើ

-ប្រៃសណីយ៍ និងទូរគមនាគមន៍

-ការពារប្រទេសជាតិ

-សន្តិសុខជាតិ

-រូបិយវត្ថុ

-នយោបាយក្រៅប្រទេស

-គោលនយោបាយសារពើពន្ធ

-និងវិស័យផ្សេងៗទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

+.**ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់** លេខ១៨៨២ប្រ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២

-**ជំពូកទី៧ អំពីដំណោះស្រាយជម្លោះ**

+<u>ប្រការ៣៨</u> នៃ(ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ លេខ១៨៨២ប្រ.ក **ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២**) បានចែងថា អភិបាលខេត្ត ក្រុង ត្រូវសម្របសម្រួលរវាងឃុំ សង្កាត់ពីរ ឬច្រើន អំពីបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់ឬមានជម្លោះជាមួយគ្នា ហើយដែលឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន។

ការដោះស្រាយរបស់អភិបាលខេត្ត ក្រុង ត្រូវឈរលើមូលដ្ឋាននៃការគោរពនូវផលប្រយោជន៍ទាំងសងខាង។

អភិបាលខេត្ត ក្រុង ត្រូវសហការ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋចំពោះឃុំ សង្កាត់ឬសេចក្តីសំរេចឬសកម្មភាពរបស់ក្រសួង ស្ថាប័នឬភ្នាក់ងារទាំងនោះ។

+<u>ប្រការ៣៩</u> នៃ(ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ លេខ១៨៨២ប្រ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២) បានចែងថា ក្នុងករណីដែលអភិបាលខេត្ត ក្រុង បានដោះស្រាយណាមួយដែលមានភាពប្រទាញប្រទង់ឬមានជម្លោះជាមួយគ្នា លើមូលដ្ឋាននៃការធានាបាននូវប្រយោជន៍សំរាប់គ្រប់ភាគី និងអ្នកពាក់ព័ន្ធទាំងអស់ ហើយអភិបាលខេត្ត ក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

+ប្រការ៤០ នៃ(ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ លេខ២១៨៨២ប្រ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២) បានចែងថា ក្នុងករណីដែលបញ្ហាណាមួយមានភាពប្រទាញប្រទង់ឬមានជម្លោះជាមួយគ្នា ក្រោយពីបានដោះស្រាយហើយ តែគូភាគី និងអ្នកដែលពាក់ព័ន្ធនៅតែមិនស្រុះស្រួលជាមួយគ្នា អភិបាលខេត្ត ក្រុង ត្រូវធ្វើសេចក្តីរាយការណ៍អំពីបញ្ហាទាំងនោះ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបន្តដោះស្រាយ។

+**សំណុំរឿងភាគច្រើន ដែលទទួលបានកើតមាននៅមូលដ្ឋាន មានដូចជា**[6] ៖

- ទំនាស់ដីធ្លី
- ទំនាស់អំពីការជំពាក់ប្រាក់និងកិច្ចសន្យា
- ទំនាស់រវាងប្តីឬប្រពន្ធ
- ទំនាស់អំពីបរិហាកេរ្តិ៍ឬជេរប្រមាថ
- ទំនាស់អំពីផ្តាច់ពាក្យរៀបការ
- ទំនាស់ទ្រព្យសម្បត្តិ
- ការផ្សះផ្សាលើការលែងលះ (ដោយមកពីអំពើហិង្សាក្នុងគ្រួសារ)
- បញ្ហាផ្សេងៗក្នុងគ្រួសារ
- ទំនាស់បង្កការខូចខាតទ្រព្យសម្បត្តិតូចតាច
- ការបង្ករបួសស្នាមតូចតាច
- ករណីផ្សេងៗទៀត

+ **សំណុំរឿងទំនាស់ដែលមិនអាចធ្វើការសម្រុះសម្រួល គឺមាន**[7] ៖

-សំណុំរឿងដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋដូចជា ការរំលោភ ឃាតកម្មជាដើម

-សំណុំរឿងដែលភាគីមិនមានឆន្ទៈចូលរួមដោយស្ម័គ្រចិត្តនៅក្នុងការសម្រុះសម្រួល

-សំណុំរឿងដែលភាគីមួយ ឬទាំងពីរបានតាំងចិត្តថានឹងប្តឹងទៅកាន់តុលាការ

-សំណុំរឿងដែលមានទំនាស់ផលប្រយោជន៍រវាងភាគីនិងអ្នកសម្រុះសម្រួល

-សំណុំរឿងដែលអាជ្ញាធរមានសមត្ថកិច្ចណាមួយកំពុងដោះស្រាយ ឬចាត់ការ

-ទំនាស់ដែលច្បាប់បានប្រគល់ឬកំណត់យ៉ាងច្បាស់ទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗ

6 សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី១៦

7 សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី២១

**<u>សូមបញ្ជាក់</u>**

-ក្នុងករណីមួយចំនួនដែលគណៈកម្មាធិការនេះមិនគួរធ្វើការផ្សះផ្សានោះទេ ជាក់ស្តែង[8] ដូចជា រឿងព្រហ្មទណ្ឌ ឧទាហរណ៍ដូចជាករណីរំលោភ ឬសម្លាប់ រឿងដីធ្លី ដែលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) វិវាទដែលភាគីមិនយល់ព្រមទទួលយកនូវការផ្សះផ្សា និងវិវាទដែលសន្ធានការី ឬអ្នកផ្សះផ្សាមានទំនាស់ផលប្រយោជន៍ជាមួយនឹងភាគីវិវាទ។

*** *** ***

---

[8] ឯកសារស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់វិទ្យាស្ថានសភាកម្ពុជា ( PIC ) ទំព័រទី១២

II. **អំពីមាត្រាមួយចំនួននៃច្បាប់ និងប្រការទាំងឡាយនៃលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយទំនាស់នៅឃុំ សង្កាត់ដែលគួរយល់ដឹង ៖**

+.**អំពីអំពើហិង្សាក្នុងគ្រួសារ** (*ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥*)

*__មាត្រា៣៣__ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថារដ្ឋ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំ ផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋទូទាំងប្រទេសបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះជាពិសេសអំពីការទទួលខុសត្រូវ ក្នុងគ្រួសារ ការគោរពសិទ្ធិគ្នាទៅវិញទៅមក ដើម្បីលើកស្ទួយតម្លៃគ្រួសារខ្មែរ សីលធម៌ សុជីវធម៌ ការរស់នៅ ការថែរក្សា និងការអប់រំគ្រួសារ របៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធីព្រមទាំងណែនាំឲ្យយល់ពីវិធានការទាំងឡាយក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារដល់ជនរងគ្រោះ។*

*រដ្ឋជម្រុញភាគីដែលមានវិបត្តិអំពើហិង្សាក្នុងគ្រួសារឲ្យចូលរួមក្នុងវគ្គពិគ្រោះបញ្ហា ដើម្បីរៀនសូត្រស្វែងយល់អំពីវិធីសាស្ត្រនានាក្នុងការដោះស្រាយទំនាស់ និងអប់រំដោយមិនប្រើប្រាស់អំពើហិង្សា។*

*__មាត្រា៣៦__ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយបើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌតុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ។*

*__មាត្រា១៧__ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថាក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមាន __សមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បី ផ្សះផ្សា ឬសម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរបានទេ។__*

## -ដីកាការពារសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

__មាត្រា១៦__ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុងដើម្បីសុំឲ្យចេញដីកាការពារ។ ចៅក្រមដែលទទួលចាត់ការត្រូវចេញដីកាការពារដោយមានវត្តមានឬពុំចាំបាច់មានវត្តមានជនមុខសញ្ញា។

__មាត្រា២៣__នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា ដីកាការពារមានពីរដំណាក់កាល :

១-ដំណាក់កាលទី១ ហៅថាដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល ២(ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ។

២-ដំណាក់កាលទី២ ហៅថាដីកាការពារមានរយៈពេល៦(ប្រាំមួយ)ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬមុនមានសាលក្រមស្ថាពរ។

__មាត្រា២__ អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ ៖ ១.ប្តី ឬប្រពន្ធ។ ២.កូនក្នុងបន្ទុក។ ៣.ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។

__មាត្រា១៣__ ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើត ឬជឿជាក់ថានឹងកើតឡើងអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយៈ

-ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែងដែលជនមុខសញ្ញាបាន ឬអាចប្រើប្រាស់

-បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះបើមានការស្នើសុំពីជនរងគ្រោះ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។

-ផ្តល់ឲ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្ន ដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់។

-ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឲ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងក្នុងមាត្រា២០ និងមាត្រា២៦ នៃច្បាប់នេះ។ ជនមុខសញ្ញាក្នុងច្បាប់នេះ គឺសំដៅដល់អ្នកដែលបានប្រព្រឹត្តកំពុងប្រព្រឹត្ត និងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។

មាត្រា១៤ ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចរដ្ឋបាលស្របតាមមាត្រា៤៣ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចាត់វិធានការបណ្តោះអាសន្ន ស្របច្បាប់ដែលមានជាអាទិ៍ ៖

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង

-ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឲ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ

-ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច

-ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ។

មាត្រា១៥ បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើតមានឡើងហើយអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅក្នុង ទីកន្លែងកើតហេតុទោះជាពុំមានដីកាតុលាការអនុញ្ញាតឲ្យចូលក៏ដោយក្នុងករណីទាំងឡាយណាដែលមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ចយល់ដោយសមហេតុផលថា មានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល៤៨ម៉ោងកន្លងផុត ឬនឹងអាចកើតឡើងក្នុងអំឡុងពេល២៤ម៉ោងខាងមុខ។ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឲ្យបានជាក់លាក់អំពីហេតុការណ៍នោះរួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច។

មាត្រា១៦ ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឲ្យចេញដីកាការពារ។ ចៅក្រមដែលទទួលបន្ទុកការត្រូវចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានជនមុខសញ្ញា។

មាត្រា១៧ ក្នុងការចូលរួមអនុវត្តន៍នីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬសម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរបានទេ។

មាត្រា១៨ អាជ្ញាធរមានសមត្ថកិច្ចអាចឃាត់ខ្លួនជនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការដូចមានចែងក្នុង មាត្រា២៤ និងមាត្រា២៥ នៃច្បាប់នេះដោយពុំចាំបាច់មានដីកាតុលាការ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ចដែលពុំមានដីកាពីតុលាការត្រូវហាមឃាត់។ ក្នុងករណីអនុវត្តន៍តាមបញ្ញត្តិនៃវាក្យខណ្ឌទី១ ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់កសាងសំណុំរឿង និងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ក្នុងអំឡុងពេលអតិបរិមាដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីចាត់វិធានការបន្ថែមឲ្យស្របច្បាប់។

មាត្រា១៩ អំពើហិង្សាក្នុងគ្រួសារណាដែលមានចរិកជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញាទោះអំពើហិង្សានេះបាន កន្លងផុតហើយក៏ដោយ។ បណ្តឹងអាជ្ញាត្រូវធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់នេះ និងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន។

+.**អំពីអាពាហ៍ពិពាហ៍** (ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)

-ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា(ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)

(ការដាក់ពាក្យសុំអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍)

*មាត្រា៩៥៩ នៃក្រមរដ្ឋប្បវេណី*

១-អាពាហ៍ពិពាហ៍ នឹងមានអានុភាពដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

២-ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអាត្រានុកូលដ្ឋាន។

**-អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ខែធ្នូឆ្នាំ ២០០០**

*មាត្រា២៨ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន*

បុរស នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃ ឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឲ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

*មាត្រា២៩នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន*

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះផ្សាយជាសាធារណៈនៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់នៃសាមីខ្លួននារី០១ច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំឬសង្កាត់ ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំឬសង្កាត់នៃសាមីខ្លួន បុរស០១ច្បាប់។ ប័ណ្ណប្រកាសត្រូវចុះ ៖

១-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅនៃអនាគត ប្តី ប្រពន្ធ។

២-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅរបស់ឪពុក ម្តាយនៃអនាគតប្តី ប្រពន្ធ បើឪពុកឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់។

៣-រយៈពេលប្តឹងជំទាស់

បណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបានប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់។

<u>មាត្រា៣០នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

អាពាហ៍ពិពាហ៍ និងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជា ប្តី ប្រពន្ធចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី។

កិច្ចសន្យានេះត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន០២នាក់ផង។

<u>មាត្រា៣១នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

ពេលសាមីខ្លួនជាអនាគត ប្តី និងប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍រួចហើយត្រូវប្រគល់ឲ្យសាមីខ្លួនប្តី ប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។

<u>មាត្រា៣៤០ នៃក្រមព្រហ្មទណ្ឌ បទទ្វេពន្ធភាព</u>

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ទៅ១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល អំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមុនការរំលាយអាពាហ៍ពិពាហ៍ចាស់។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះមន្ត្រីអត្រានុកូលដ្ឋានដែលដឹងហេតុការណ៍នោះច្បាស់ នៅតែអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ ឬចុះបញ្ជីអាពាហ៍ពិពាហ៍នេះមុនការរំលាយអាពាហ៍ពិពាហ៍ចាស់។

-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦)

ប្រការ១៨ (នៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម៖

-ប្រកាសអន្តរក្រសួងលេខ៣៨៩៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ប្រកាសអន្តរក្រសួងលេខ ៦៧៤៤ ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការកែប្រែកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ៣៨៩៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **ឃ.រដ្ឋបាលឃុំ សង្កាត់** | | | | | **ចំនួន** |
| **១-ការងារអត្រានុកូលដ្ឋាន** | | | | | |
| ៤ | បណ្ណប្រកាសអាពាហ៍ពិពាហ៍ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេសជាមួយពលរដ្ឋខ្មែរ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៧ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |

**-អនុក្រឹត្យស្តីពីការកំណត់បែបបទនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស លេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨**

*មាត្រា២ នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា*

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា។

*មាត្រា៣នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា*

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងារ ភើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម។

*មាត្រា៤នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា*

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោតក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។

*មាត្រា៥នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា*

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។

*មាត្រា៦នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា*

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃ

ព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោមៈ

-ពាក្យសុំរៀបអាពាហ៍ពិពាហ៍

-ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជាដែលនៅមានសុពលភាព

-លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

-លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា

-លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

-លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលជានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវឬពោះម៉ាយឬមេម៉ាយត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូតឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយ ពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ១០៥ថ្ងៃការងារ។ ក្រោយពីបានពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ជូនសំណុំឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ និងជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ។

**មាត្រា៨នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា**

បន្ទាប់ពីទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃមានភារកិច្ច :

-ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេស វិញក្នុងរយៈពេលយ៉ាងយូរ១០ថ្ងៃការងារ។

-ជូនដំណឹងអំពីការសុំអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

-ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

<u>មាត្រា៩នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា</u>

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារនិង បានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម:

-ពាក្យសុំរៀបអាពាហ៍ពិពាហ៍

-សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ

-លិខិតបញ្ជាក់ភាពនៅលីវឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

-លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេស និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នាទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

<u>មាត្រា១០នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា</u>

មន្ត្រីអត្រានុកូលដ្ឋានឃុំសង្កាត់ មានភារកិច្ចពិនិត្យ និងសំរេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនបុរសនិងនារី <u>ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃការងារ</u> បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់។

បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរសនិងនារីបានត្រឹមត្រូវតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួន បុរសនិងនារីចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវ<u>បិទផ្សាយរយៈពេល១០ថ្ងៃនៅស្ថានទូតឬស្ថានតំណាងនៃប្រទេស</u> សាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានអចិន្ត្រៃយ៍និងនៅសាលាឃុំសង្កាត់នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។ <u>ផុតរយៈពេល១០ថ្ងៃ ប្រសិនគ្មានការប្តឹងតវ៉ាឬប្តឹងជំទាស់</u> នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន។

<u>មាត្រា១១នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានចែងថា</u>

<u>អាពាហ៍ពិពាហ៍ នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍</u>តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ

សង្កាត់ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន០២រូបផងស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

មាត្រា៣២នៃអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន

ការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសដែលគូភាគីមានទីលំនៅ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាង ពលរដ្ឋខ្មែរនិងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ឬសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះឬបើប្ដី ប្រពន្ធមកតាំងលំនៅ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំឬសង្កាត់ ដែលខ្លួនបានរស់នៅ។ ស្ថានទូត ស្ថានអគ្គកុងស៊ុលឬស្ថានកុងស៊ុលឬមន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី ឲ្យទៅជននោះយកទៅប្រើប្រាស់។

មាត្រា៣៣នៃអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន

អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣៤នៃអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន

ជនអន្តោប្រវេសន៍និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសឬ

ជនអន្តោប្រវេសន៍នោះបានដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន ដោយប្រាប់ពីទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះឲ្យបានច្បាស់។

ពេលរៀបអាពាហ៍ពិពាហ៍ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅស្ថានទូត ស្ថានអគ្គកុងស៊ុលឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាក៏បាន។

ការចុះឈ្មោះនៃជនជាតិបរទេសត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង។

**<u>មាត្រា៩៩៧</u>នៃក្រមរដ្ឋប្បវេណី ទម្រង់នៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែលរស់នៅបរទេស**

១-បើមានបំណងចង់រៀបអាពាហ៍ពិពាហ៍រវាងគ្នា ពលរដ្ឋខ្មែរដែលរស់នៅបរទេសអាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជូនដំណឹងជាសាធារណៈចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងចុះបញ្ជីអាពាហ៍ពិពាហ៍នោះ នៅចំពោះមុខឯកអគ្គរាជទូត ការធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ។

២-ការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវធ្វើដោយបិទនៅបញ្ចររបស់ស្ថានទូតឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ។

**-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ លេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦)**

<u>ប្រការ១៨</u> នៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាល ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម ៖

-ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ប្រកាសអន្តរក្រសួងលេខ ៦៧៤២ ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការកែប្រែកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ខែធ្នូ ឆ្នាំ២០១៦
ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ឃ.រដ្ឋបាលឃុំ សង្កាត់ | | | | | ចំនួន |
|---|---|---|---|---|---|
| ១-ការងារអត្រានុកូលដ្ឋាន | | | | | |
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេសជាមួយពលរដ្ឋខ្មែរ) | ០៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |

**-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ លេខ១៤៤ ១៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦)**

<u>ប្រការ៨</u>នៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម ៖

-ប្រកាសអន្តរក្រសួងលេខ២០៨៧ ប្រក ចុះថ្ងៃទី១៥ ខែតុលាឆ្នាំ២០១០ ស្តីពីការកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-ប្រកាសអន្តរក្រសួងលេខ ៣៦៦៦ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

-ប្រកាសអន្តរក្រសួងលេខ ៨០២៨ ប្រក ចុះថ្ងៃទី២៨ ខែតុលាឆ្នាំ២០១៦ ស្តីពីការកែសម្រួលកម្រងសេវារដ្ឋបាលនៃតារាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួង. លេខ៣៦៦៦ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។

តារាងឧបសម្ព័ន្ធ

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **ខ.កិច្ចការអត្រានុកូលដ្ឋាន** | | | | | |
| ៤ | ការស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយប្រជាពលរដ្ឋខ្មែរ | 0៛ | ២៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |

+ **ការសម្រុះសម្រួលលើករណីរឿងលែងលះ**

រឿងលែងលះ គឺទំនងជារឿងដែលមានភាពលំបាកបំផុតក្នុងចំណោមរឿងលំបាកជា ច្រើន[9] ដែលត្រូវដោះស្រាយដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ប្រសិនបើរឿងនោះត្រូវបានគេប្តឹងឡើងដោយសារមូលហេតុចេញមកពីអំពើហិង្សានៅក្នុងគ្រួសារ។ តើគួរធ្វើ ឬមិនធ្វើការសម្រុះសម្រួលទៅលើរឿងទាំងនេះ ឬក៏ផ្តល់នូវដំបូន្មានផ្នែកច្បាប់ទៅលើនីតិវិធី នៃការលែងលះ ដើម្បីបំរើសេវាសម្រុះសម្រួលទៅដល់ភាគីទំនាស់ឲ្យអស់ពីចិត្ត។

យុត្តាធិការ (អំណាចតុលាការ) ក្នុងរឿងលែងលះ គឺស្ថិតនៅលើសាលាដំបូង ដូចនេះ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មន្ត្រីមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ ស្រុក ក្រុងឬអាជ្ញាធរមូលដ្ឋានពុំមាននីត្យានុកូលភាព (អំណាចផ្លូវច្បាប់) ដើម្បីសម្រេចលើរឿងលែងលះនោះទេ។

នៅពេលខ្លះ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ អាចធ្វើសម្រុះសម្រួលលើ[10] ករណីដែលភាគីទាមទារចង់ធ្វើការលែងលះបាន ប៉ុន្តែ

---

[9] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី២២
[10] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី២៣

សម្រាប់តែនៅពេលដែលភាគីបង្ហាញច្បាស់លាស់ថា គេប្រាកដជាចង់ធ្វើការសម្រុះសម្រួលរឿងវិវាទរបស់គេមុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។

+ក្នុងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី

<u>មាត្រា៩៨២</u> នៃក្រមរដ្ឋប្បវេណី បណ្តឹងនៃការលែងលះគ្នា

១-ពាក្យបណ្តឹងលែងលះគ្នា អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ចដោយយោងតាមបញ្ញត្តិមាត្រា១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុត្តភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

២-ភាគីអាចដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬទីសំណាក់ ដូចបានកំណត់នៅកថាខណ្ឌទី១ និងទី៣ នៃ មាត្រា១០(សមត្ថកិច្ចសាលាជម្រះក្តី ពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុត្តភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។ក្នុងករណីនេះក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឲ្យសះជាគ្នាបានក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលឲ្យសះជាគ្នាបានទេត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នាហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅតុលាការជាបន្ទាន់។

<u>មាត្រា៩៨២</u> **នៃក្រមរដ្ឋប្បវេណី** ការសាកល្បងផ្សះផ្សាដោយតុលាការ

១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។

២-បើការផ្សះផ្សាពុំអាចសម្រេចបានទេតុលាការត្រូវយកបណ្តឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យហើយធ្វើការប្រកាសសាលក្រម។

<u>មាត្រា៩៧</u> **នៃក្រមនីតិវិធីរដ្ឋប្បវេណី** ការសាកល្បងធ្វើការផ្សះផ្សា

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។

<u>មាត្រា៩៧៨</u> **នៃក្រមរដ្ឋប្បវេណី** មូលហេតុនៃការលែងលះគ្នា

១-ប្តីឬប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែល

កំណត់ខាងក្រោមនេះ :

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាង១(មួយ)ឆ្នាំ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១(មួយ)ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។

២-ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះក៏ដោយប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធឬកូនក្រលំបាកយ៉ាងខ្លាំងឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោល ការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។

៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬចំណុច ង នៃកថាខណ្ឌទី១ ខាងលើនេះប្រសិនបើយល់ឃើញថាការទាមទារនោះផ្ទុយនឹងភាពសុចរិតដោយជនដែលទាមទារឲ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន។

## ការស្នើសុំធ្វើការលែងលះតាមផ្លូវច្បាប់

-ចំពោះករណីរឿងលែងលះ មានតែតុលាការខេត្ត ក្រុងទេ ដែលអាចផ្តល់នូវសេចក្តីសម្រេចបាន។ ការចេញសេចក្តីសម្រេចប្រភេទផ្សេងទៀតនៃការលែងលះឲ្យភាគីក្រៅពីតុលាការគឺខុសច្បាប់[11]។

[11] សៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ទំព័រទី២៥

+**អំពីការផ្តាច់ពាក្យរៀបការ**( ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)

-មាត្រា៩៤៥ នៃក្រមរដ្ឋប្បវេណី ការសងជំនូន ក្នុងករណីដែលកំជាប់ពាក្យ[12] បានរលាយ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឲ្យភាគីម្ខាងទៀតសងជំនូននោះមកវិញបាន។

-មាត្រា៩៤៦ នៃក្រមរដ្ឋប្បវេណី ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគីចោលដោយគ្មានមូលហេតុត្រឹមត្រូវភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន។

-មាត្រា៩៤៧ នៃក្រមរដ្ឋប្បវេណី អំឡុងពេលដាក់ពាក្យបណ្តឹង បណ្តឹងដែលទាក់ទង ទៅនឹងមាត្រា៩៤៥ (ការសងជំនូន) ឬមាត្រា៩៤៦(ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្តឹងនៅក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះ បានរលាយ។

+**អំពីទ្រព្យសម្បត្តិ**( ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)

-មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណី បានចែងថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុនឬក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ។

២-បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់)។

---

12 កំជាប់ពាក្យ ពិធីតាមទំនៀមទម្លាប់ប្រពៃណីដែលច្បាប់ទទួលស្គាល់ដែលតាមរយៈពិធីនេះ បុរសនិងនារីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

-មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណី បានចែងថា ភាពចាំបាច់នៃទម្រង់ជាលាយល័ក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងល័ក្ខខ័ណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ។

២-ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់បើមិនបានចុះបញ្ជីទេមិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយ នឹងតតិយជនបានឡើយ។

**-មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី** បានចែងថា ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះគឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិ របស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយ**ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន**[13] នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច **ក** និងចំណុច **ខ** ខាងលើនេះ ។

**-មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី** បានចែងថា ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួមគឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច **ខ** និងចំណុច **គ** នៃមាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ។

-មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណី បានចែងថា ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិ

---

[13]-ប្រទានកម្មជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឲ្យទៅភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគី ម្ខាងទៀតយល់ព្រមទទួល។

-សន្តតិកម្ម ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មតករជនទៅឲ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។

-អច្ច័យទាន ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍

១-ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផល ប្រយោជន៍ និងគ្រប់គ្រង ទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធ ម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀតឲ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បី គ្រប់គ្រងនិងរក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។

៤-បើការពិភាក្សាអំពីការគ្រប់គ្រងឬប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តី ប្រពន្ធមិនបានសម្រេចឬបើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារ ទៅតុលាការឲ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ រួមបាន។

<u>-មាត្រា៩៧៦</u> **នៃក្រមរដ្ឋប្បវេណី** បានចែងថា <u>ការចាត់ចែងទ្រព្យសម្បត្តិ រួមរបស់ប្តីប្រពន្ធ</u>

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ ប្តីប្រពន្ធមិនអាចយកទៅលក់ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើក៏ដោយ បើមានស្ថានភាព មិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍និងដើម្បី រក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ឬធ្វើការចាត់ចែងផ្សេង ទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ។

៣-ក្នុងករណីដែលប្តីឬប្រពន្ធណាម្ខាង បានលក់ឬធ្វើការចាត់ចែងផ្សេង ទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាច ទាមទារឲ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាន នៅក្នុងអំឡុងពេល ២(ពីរ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិ

រួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុនឹងនៅក្នុងអំឡុងពេល១ (មួយ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង។

-<u>មាត្រា៩៨០</u> នៃក្រមរដ្ឋប្បវេណី បានចែងថា <u>ការបែងចែកទ្រព្យសម្បត្តិ</u>

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកតាមចំណុចនីមួយៗដូចកំណត់ខាងក្រោមនេះ :

ក-សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ភាគ២(មួយភាគពីរ)នៃទ្រព្យសម្បត្តិរួម។ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្នាក់ តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។

+<u>**អំពីដំណើរ**</u>

+ឃុំគប្បីសំរបសំរួលអំពីទស្សនៈប្រជាជនដើម្បីឲ្យមានការយោគយល់គ្នាទៅវិញទៅមក ។

+ការដោះស្រាយតាមគោលការណ៍ស្ម័គ្រចិត្តនៃគូរភាគីទំនាស់។

+ផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ពាក់ព័ន្ធ។

+ចង្អុលបង្ហាញនីតិវិធីផ្នែកច្បាប់បន្តទៀតករណីភាគីទំនាស់មិនព្រមសះជាគ្នា។

**+ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលប្រការ៩ នៃប្រកាសអន្តរក្រសួង លេខ២១៥ ប្រក/ជនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំសង្កាត់ក្នុងការចុះបញ្ជីដីធ្លី លេខ១៥៩ ប្រក/ជនស./មផ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់**

-ប្រការ៩ថ្មី បានចែងថា មេឃុំ ចៅសង្កាត់ ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជាលិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាជួលរយៈពេលវែង កិច្ចសន្យាបង្កើតសេវភាព ផលុបភោគអាស្រ័យលើការព្រមព្រៀងរបស់គូភាគី។ ក្នុងការបញ្ជាក់ មេឃុំ ចៅសង្កាត់ ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើះ

-អត្តសញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុនៃលិខិតកិច្ចសន្យានិង

-អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា។

<u>-មាត្រា១៣៨</u> **នៃក្រមរដ្ឋប្បវេណី** និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាននៅក្នុងទំហំដែលច្បាប់បានកម្រិត ។

<u>-មាត្រា១៣៩</u> **នៃក្រមរដ្ឋប្បវេណី** កម្រិតនៃកម្មសិទ្ធិដី

១-កម្មសិទ្ធិដី ត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកក្រោមដីនៅក្នុងទំហំនៃការកម្រិតដែលច្បាប់និងបទដ្ឋានគតិយុត្តបានកំណត់ហើយក្នុងទំហំដែលមានផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ។

២-កម្មសិទ្ធិករនៃដីមិនអាចប្រើប្រាស់ដីរបស់ខ្លួនក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬរំខានដល់ជីវភាពរស់នៅរបស់អ្នកដទៃតែប៉ុណ្ណោះបានឡើយ។

<u>-មាត្រា១៤០</u> **នៃក្រមរដ្ឋប្បវេណី** ការបញ្ឈប់អំពើដែលរំខានដល់ជីវភាពរស់នៅ

១-ក្នុងករណីដែលអំពើរំខានដល់ជីវភាពរស់នៅដែលមកពីឧស្ម័ន ចំហាយទឹក ក្លិនផ្សេង ម្រែងភ្លើង កំដៅ សម្លេង រំញ័រ ជាអាទិ៍ ដែលកើតពីដី

របស់អ្នកដទៃ ស្ថិតនៅក្នុងទំហំនៃការប្រើប្រាស់ជាធម្មតា ហើយបទដ្ឋានគតិយុត្ត មិនបានហាមឃាត់ទេ កម្មសិទ្ធិករនៃដីមិន អាចទាមទារឲ្យអ្នកដទៃបញ្ឈប់នូវអំពើដែលធ្វើឲ្យមានឥទ្ធិពលដល់ដីខ្លួនបានឡើយ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះកម្មសិទ្ធិករនៃដី ដែលទទួលឥទ្ធិពលអាក្រក់ដ៏ធ្ងន់ធ្ងរ តាមភាពជាក់ស្តែង អាចទាមទារឲ្យអ្នកដែលរំខានដល់ជីវភាពរស់នៅនោះសងសំណងសមរម្យបាន។ ម៉្យាងទៀត បញ្ញត្តិនេះមិនរារាំងកម្មសិទ្ធិករដី ក្នុងការទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលឡើយ។

<u>-មាត្រា១៨១</u> **នៃក្រមរដ្ឋប្បវេណី** ការជីកកកាយបេតិកភណ្ឌវប្បធម៌ និងរ៉ែក្នុងដី

១-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើគ្រប់ប្រភេទនៃបដិមាចម្លាក់ក្រឡោត បុរាណវត្ថុ ឬបេតិកភណ្ឌវប្បធម៌ផ្សេងទៀតដែលរកឃើញនៅក្នុងដីរបស់ខ្លួនបានឡើយ។ វត្ថុទាំងនេះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋហើយកម្មសិទ្ធិករនៃដីដែលបានរកឃើញវត្ថុទាំងនេះ មានករណីយកិច្ចប្រគល់ឲ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

២-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើរ៉ែ នៅក្នុងដីដែលបានកំណត់នៅក្នុងច្បាប់ផ្សេងបានឡើយ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអ្នកដែលត្រូវបាន ទទួលស្គាល់នូវសិទ្ធិជីកដោយរដ្ឋតាមបញ្ញត្តិនៃច្បាប់ផ្សេងមានសិទ្ធិជីក និងទទួលវត្ថុនោះ។

<u>-មាត្រា១៨២</u> **នៃក្រមរដ្ឋប្បវេណី** សិទ្ធិកាប់ចោលមែកឈើឆ្លងព្រំដី

នៅពេលដែលមែកឈើ ឬឫសឈើនៃដីជិតខាងបានលយចូលមកដីរបស់ខ្លួនកម្មសិទ្ធិករនៃដីអាចយកផលពី មែកឈើ ឬ ឫសឈើនោះ ឬកាប់មែកឈើ ឬឫសឈើនោះបាន ។

<u>-មាត្រា១៨៣</u> **នៃក្រមរដ្ឋប្បវេណី** សិទ្ធិប្រើដីដែលជាប់គ្នា

កម្មសិទ្ធិករនៃដីអាចទាមទារប្រើដីដែលជាប់គ្នាបាន ក្នុងទំហំចាំបាច់ដើម្បីធ្វើរបងឬ សង់សំណង់ឬជួសជុលរបស់ទាំងពីរនេះ នៅព្រំប្រទល់ដីឬនៅក្បែរព្រំប្រទល់នោះ។ ប្រសិនបើអ្នកជិតខាងទទួលការខូចខាតដោយសារការសាងសង់ឬជួសជុលនេះកម្មសិទ្ធិករនៃដីត្រូវបង់ប្រាក់សំណង។

-មាត្រា១៤៤ នៃក្រមរដ្ឋប្បវេណី សិទ្ធិចេញចូលដីបិទជិត

១-ដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ និងដីដែលមានច្រកចេញនោះមិនគ្រប់គ្រាន់ហើយមានឧបសគ្គដ៏ខ្លាំងដើម្បីប្រើប្រាស់ដីនោះសម្រាប់ការធ្វើកសិកម្មឬឧស្សាហកម្ម ហៅថាដីបិទជិត។

២-កម្មសិទ្ធិករនៃដីបិទជិតមានសិទ្ធិស្នើសុំឆ្លងកាត់ដីអ្នកជិតខាងបានដោយបង់ប្រាក់សំណងតាមការខូចខាតដោយសារការឆ្លងកាត់នោះ។

៣-ជាគោលការណ៍ សិទ្ធិឆ្លងកាត់នេះ ត្រូវរៀបចំតាមទិស ឬផ្លូវដែលមានចម្ងាយជិតបំផុតពីដីបិទជិតទៅផ្លូវសាធារណៈ។ទោះបីជាមានបញ្ញត្តិនៃវាក្យខណ្ឌទី១នៃកថាខណ្ឌនេះក៏ដោយសិទ្ធិឆ្លងកាត់នេះត្រូវតែរៀបចំនៅកន្លែងណាដែលមានការខូចខាតតិចបំផុតសម្រាប់កម្មសិទ្ធិករនៃដីដែលទទួលបន្ទុកឲ្យឆ្លងកាត់នោះ។

៤-ប្រសិនបើដីបិទជិត កើតឡើងពីការបែងចែកដីតាមរយៈការលក់ ការដូរការចែកមត៌កឬកិច្ចសន្យាផ្សេងទៀតសិទ្ធិឆ្លងកាត់អាចស្នើសុំបានតែចំពោះដីដែលនៅសល់ក្រោយពីការបែងចែកនោះប៉ុណ្ណោះ។ ក្នុងករណីនេះកម្មសិទ្ធិករនៃដីបិទជិតមិនចាំបាច់បង់ប្រាក់សំណងឡើយ។ ប៉ុន្តែក្នុងករណីដែលមិនមានច្រកចេញគ្រប់គ្រាន់ទេ បញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ។

-មាត្រា១៤៥ នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ

១-កម្មសិទ្ធិករនៃដីក្រោម មានករណីយកិច្ចទទួលទឹកដែលហូរតាមធម្មជាតិពីដីលើ។ កម្មសិទ្ធិករនៃដីក្រោមមិនអាចលើកទំនប់ ភ្លឺ របាំង ឬការ្យ[14]ផ្សេងទៀតទប់មិនឲ្យទឹកហូរបានឡើយ។ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើអំពើអ្វីបន្ថែមបន្ទុករបស់កម្មសិទ្ធិករនៃដីក្រោមបានឡើយ។

២-ពេលមានការប្រែប្រួលដោយប្រធានសក្តិដែលគ្មានការទទួលខុសត្រូវរបស់ភាគីធ្វើឲ្យរាំងស្ទះទឹកហូរនៅដីក្រោមកម្មសិទ្ធិករនៃដីលើអាចធ្វើប្រឡាយឲ្យទឹកហូរដោយចេញសោហ៊ុយផ្ទាល់ខ្លួនបាន។

-មាត្រា១៤៦ នៃក្រមរដ្ឋប្បវេណី សិទ្ធិប្រើទឹកភ្លៀង ជាអាទិ៍

យោងទៅតាមវាក្យខណ្ឌទី៣ កថាខណ្ឌទី១ មាត្រា១៤៥ (ករណីយកិច្ច

---

[14] ការ្យគឺជាផលអ្វីទាំងពួងដែលកើតមកពីស្នាដៃជាងឬស្នាដៃសិល្បករ។ល។

ទទួលទឹកហូរតាមធម្មជាតិ) នៃក្រមនេះ កម្មសិទ្ធិករនៃដីលើ មានសិទ្ធិប្រើប្រាស់ទឹកដែលមានប្រភពផុសឡើងនៅដីរបស់ខ្លួន និងទឹកភ្លៀងដែលធ្លាក់មកលើដីរបស់ខ្លួន និងមានសិទ្ធិបង្ហូរចោលទឹកទាំងអស់នោះ។

-មាត្រា១៤៧ នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចរក្សាការពារទឹកហូរ

កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់ផ្លូវទឹកហូរ មានករណីយកិច្ចទុកឲ្យទឹកហូរទៅលើដីអ្នកជិតខាងតាមតម្រូវការនៃកសិកម្មហើយកម្មសិទ្ធិករនៃដីជិតខាងក៏មានករណីយកិច្ចដូចគ្នាដែរដោយយោគយល់ចំពោះដីដែលនៅឆ្ងាយទៀត។

-មាត្រា១៤៨ នៃក្រមរដ្ឋប្បវេណី សិទ្ធិធ្វើផ្លូវទឹកដើម្បីស្រោចស្រព

កម្មសិទ្ធិករដែលចង់ឲ្យទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់ ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើ និងរក្សាទុកនូវផ្លូវទឹកឆ្លងកាត់ដីដែលស្ថិតនៅចន្លោះប្រភពទឹកនឹងដីរបស់ខ្លួនបានដោយបង់ប្រាក់សំណងនៃការខូចខាតដល់កម្មសិទ្ធិករនៃដីដែលត្រូវឆ្លងកាត់នោះ។

-មាត្រា១៤៩ នៃក្រមរដ្ឋប្បវេណី សិទ្ធិបង្ហូរចោលទឹកស្រោចស្រព

កម្មសិទ្ធិករនៃដីអាចបង្ហូរចោលទឹកដែលបានស្រោចស្រពលើដីរបស់ខ្លួនឆ្លងកាត់ដីក្រោមបានដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីក្រោមនោះ។

-មាត្រា១៥០នៃក្រមរដ្ឋប្បវេណី សិទ្ធិបង្ហូរទឹកចោលនៃកម្មសិទ្ធិករនៃដីលិចទឹក

កម្មសិទ្ធិករនៃដីលិចទឹកទាំងស្រុងឬមួយចំណែកអាចបង្ហូរទឹកដែលបណ្ដាលឲ្យមានការខាតចេញពីដីរបស់ខ្លួនបានលុះត្រាតែគោរពបញ្ញត្តិនៃច្បាប់ឬបទដ្ឋានគតិយុត្តស្ដីពីអនាម័យ។

-មាត្រា១៥១ នៃក្រមរដ្ឋប្បវេណី សិទ្ធិលើក និងសិទ្ធិប្រើប្រាស់ទំនប់ជាអាទិ៍

១-កម្មសិទ្ធិករនៃដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ដែលចង់ប្រើប្រាស់ទឹកទន្លេ ស្ទឹងឬ ព្រែក ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើសិល្បៈការ្យ[15]ចាំបាច់ ដើម្បីយកទឹកនៅលើដីដែលស្ថិតនៅមាត់ទឹកម្ខាងទៀត បានដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីនៅមាត់ទឹកម្ខាងទៀត។

---

[15] សិល្បៈការ្យគឺជាផលទាំងពួងដែលកើតពីស្នាដៃមនុស្ស។

២-កម្មសិទ្ធិករនៃដីដែលអនុញ្ញាតឲ្យធ្វើសិល្បៈការ្យនៅលើដីរបស់ខ្លួន អាចទាមទារប្រើប្រាស់រួមនូវទំនប់ទឹក ជាអាទិ៍ ពីអ្នកដែលបានធ្វើសិល្បៈការ្យនោះបានដោយយកល័ក្ខខ័ណ្ឌទទួលបន្ទុកពាក់កណ្តាលនៃសោហ៊ុយធ្វើ និង ថែទាំ។ ក្នុងករណីនេះ អ្នកដែលបានធ្វើសិល្បៈការ្យពុំមានករណីយកិច្ចបង់ប្រាក់សំណងដែលបានកំណត់នៅកថាខណ្ឌទី១ខាងលើនេះទេ ហើយអាចទាមទារឲ្យសងសំណងដែលខ្លួនបានបង់ហើយវិញបាន។

-<u>មាត្រា១៤២</u> នៃក្រមរដ្ឋប្បវេណី អំពើដែលរំខានដល់ជីវភាពរស់នៅ

កម្មសិទ្ធិករ ដែលមានបំណងធ្វើនៅលើដីរបស់ខ្លួននូវអំពើដែលនឹងអាចរំខានដល់ជីវភាពរស់នៅរបស់អ្នកជិតខាង ដោយការខួងអណ្តូង ការជីកស្នង់ ការជីករុករកឬ ដោយការទុកវត្ថុមានគ្រោះថ្នាក់ វត្ថុដែលរំខានដល់អ្នកដទៃ ឬវត្ថុគ្មានអនាម័យត្រូវអនុលោមតាមបញ្ញត្តិពិសេសដែលកំណត់អំពីចម្ងាយដែលត្រូវគោរព និងអំពើដែលត្រូវអនុវត្ត។

-<u>មាត្រា១៤៣</u> នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចដាក់រនាំងបាំងនៅបង្អួច កើយជាអាទិ៍

អ្នកដែលធ្វើបង្អួច កើយឬសិល្បៈការ្យប្រហាក់ប្រហែលរបស់ទាំងអស់នេះ ដែលសម្លឹងទៅឃើញដីផ្ទះអ្នកជិតខាងនោះ នៅចម្ងាយតិចជាង២(ពីរ) ម៉ែត្រ ពីព្រំដីអ្នកជិតខាងត្រូវដាក់រនាំងបាំង។

-<u>មាត្រា១៤៤</u> នៃក្រមរដ្ឋប្បវេណី ដើមឈើនៅជិតព្រំដី

កម្មសិទ្ធិករនៃដីមិនអាចដាំដើមឈើ គុម្ពោត ឬចុល្លព្រឹក្សដែលមានកម្ពស់លើសពី ២(ពីរ)ម៉ែត្រ ក្នុងចម្ងាយ២(ពីរ) ម៉ែត្រ ពីព្រំប្រទល់ដីអ្នកជិតខាងបានឡើយ។ ក្នុងករណីដែលធ្វើផ្ទុយពីបញ្ញត្តិនេះកម្មសិទ្ធិករនេះមានករណីយកិច្ចដកចេញតាមការទាមទាររបស់កម្មសិទ្ធិករនៃដីជិតខាង។

+**<u>អំពីបរិហារកេរ្តិ៍ជាសាធារណៈ ឬជេរប្រមាថ</u>** (ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩)

**<u>-បរិហារកេរ្តិ៍ជាសាធារណៈ</u>**

-មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ <u>បទបរិហារកេរ្តិ៍ជាសាធារណៈ</u> គ្រប់ការអះអាងបំផ្លើស ឬការទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឲ្យប៉ះពាល់ដល់កិត្តិយសឬកិត្តិស័ព្ទនៃបុគ្គលឬនៃស្ថាប័នគឺជាការបរិហារកេរ្តិ៍។

ត្រូវពិន័យជាប្រាក់ពី១០០.០០០ (មួយសែន)រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀល បទបរិហាកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយណាដូចតទៅ:

១-តាមសំដីទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ។

២-តាមលិខិតឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជនឬដាក់តាំងឲ្យសាធារណជនមើល។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។

**<u>-ជេរប្រមាថជាសាធារណៈ</u>**

-មាត្រា៣០៧នៃក្រមព្រហ្មទណ្ឌ <u>បទជេរប្រមាថជាសាធារណៈ</u> គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយឬគ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ។

ត្រូវពិន័យជាប្រាក់ពី១០០.០០០ (មួយសែន)រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀល បទជេរប្រមាថដែលប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដូចតទៅ:

១-តាមពាក្យសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ។

២-តាមលិខិតឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជនឬដាក់តាំងឲ្យសាធារណជនមើល។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។

+**អំពីការជំពាក់ប្រាក់និងកិច្ចសន្យា**( *ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧*)

*-មាត្រា៣៣៦នៃក្រមរដ្ឋប្បវេណី ការបង្កើតកិច្ចសន្យាដោយសំណើ និង**ស្ទីការ**[16]*

*១-កិច្ចសន្យាមានអានុភាពដោយសារសំណើនិងស្ទីការត្រូវគ្នា។*

*២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាង ទទួលករណីយកិច្ចធ្វើ**អនុប្បទាន**[17]នូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិ លើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។*

*-**មាត្រា៣៤៩ នៃក្រមរដ្ឋប្បវេណី** ការបង្ហាញឆន្ទៈដែលមានវិការៈ*

*អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន**វិការៈ**[18] តាមបញ្ញត្តិនៃផ្នែកទី២ (វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា) នេះ និងផ្នែកទី៣( មោឃភាព និងការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :*

*ក.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ។*

*ខ.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត។*

*គ.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណង កេងយកចំណេញហួសហេតុ។*

*-**មាត្រា៣៥២ នៃក្រមរដ្ឋប្បវេណី** ភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អក្នុងអត្ថន័យនៃកិច្ចសន្យា*

*១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈក្នុងករណីខាងក្រោមនេះ :*

[16] ស្ទីការគឺការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

[17] អនុប្បទានគឺជាការផ្ទេរសិទ្ធិឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយីទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។ ឧ អនុប្បទានភាគហ៊ុន (ការលក់ភាគហ៊ុន)។

[18] វិការៈគឺជាការប្រែប្រួលចាកពីភាពប្រក្រតី។

ក.អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។

ខ.អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែក ផ្សេងៗទៀត ក៏មិនធ្វើឲ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែបំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ។

-<u>មាត្រា៣៨២</u> នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឲ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យានិង គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវចាត់ទុកជាការសងដែលនាំ ឲ្យកាតព្វកិច្ចរលត់។

-<u>មាត្រា៣៨៤</u> នៃក្រមរដ្ឋប្បវេណីសិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច

១-ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ក៏ដោយម្ចាស់បំណុលមិនអាចទាមទារឲ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបានឡើយក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថាមិនទាមទារឲ្យអនុវត្ត តាមផ្លូវតុលាការ។

៣-ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឲ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ដោយសារមានករណីត្រូវនឹងកថាខណ្ឌទី២ ខាងលើនេះក៏ដោយ ប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តហើយ ម្ចាស់បំណុលអាចទទួល និងរក្សាទុកនូវ<u>តាវកាលិក</u>[19]នេះដោយចាត់ទុកថាជាការសងបាន។

[19]តាវកាលិក វត្ថុឬសកម្មភាពដែលជាទីតាំង (ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។

**-មាត្រា៣៨៦ នៃក្រមរដ្ឋប្បវេណី** ការតវ៉ាឲ្យអនុវត្តព្រមគ្នា

ភាគីនីមួយៗនៃកិច្ចសន្យាអញ្ញមញ្ញ[20]អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនរហូតដល់ពេលដែលភាគីម្ខាងទៀតផ្តល់នូវការអនុវត្តកាតព្វកិច្ច។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀត មិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត។

**-មាត្រា៣៨៧ នៃក្រមរដ្ឋប្បវេណី** ការតវ៉ាដោយមានការបារម្ភ

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុននៅក្នុង **កិច្ចសន្យាអញ្ញមញ្ញ** អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឲ្យកត់សម្គាល់ថាភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬចាត់ចែងវិធានការផ្សេងទៀតដើម្បីរំលត់ការបារម្ភនោះ។

**-មាត្រា៣៨៨ នៃក្រមរដ្ឋប្បវេណី** ការអនុវត្តតាមបញ្ញត្តិស្តីពីការសង

ក្រៅពីបញ្ញត្តិនៃជំពូកទី៣ (ការអនុវត្តកិច្ចសន្យា) នេះ បញ្ញត្តិស្តីពីការសងដែលបានកំណត់នៅក្នុងផ្នែកទី១ (ការសង) នៃជំពូកទី៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការអនុវត្តកិច្ចសន្យា។

**-មាត្រា៣៨៩នៃក្រមរដ្ឋប្បវេណី** និយមន័យនិងទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែល កើតឡើងពីកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមនេះ :

ក.កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឲ្យទាន់ពេលកំណត់ត្រូវអនុវត្តដោយសារការយឺតយ៉ាវក្នុងការអនុវត្ត។

ខ.អលទ្ធផលក្នុងការអនុវត្តកាតព្វកិច្ច។

គ.កូនបំណុលមិនបានអនុវត្តឲ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។

ឃ.ករណីផ្សេងៗទៀត ដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។

---

[20] កិច្ចសន្យាអញ្ញមញ្ញជាកិច្ចសន្យាដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមក ដូចជា កិច្ចសន្យាម៉ៅការ ភតិសន្យា
កិច្ចសន្យាលក់ទំនិញ។

-<u>មាត្រា៣៩០</u> នៃក្រមរដ្ឋប្បវេណី វិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច

ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលម្ចាស់បំណុលអាចទាមទារឲ្យអនុវត្តដោយបង្ខំសងសំណងនៃការខូចខាត ឬរំលាយកិច្ចសន្យាដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី២ដល់ផ្នែកទី៤ នៃជំពូកទី៤នេះបាន។

-<u>មាត្រា៣៩១</u> នៃក្រមរដ្ឋប្បវេណី ការយឺតយ៉ាវក្នុងការអនុវត្ត

កូនបំណុលត្រូវបានចាត់ទុកថាមានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ចនៅពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក.ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ចនៅពេលដល់កាលកំណត់នោះ។

ខ.ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថាដល់ពេលកំណត់ហើយ។

គ.ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេនៅពេលដែលកូនបំណុលនោះទទួលការទាមទារឲ្យអនុវត្ត។

-<u>មាត្រា៣៩២</u> នៃក្រមរដ្ឋប្បវេណី អលទ្ធភាពក្នុងការអនុវត្ត

១-ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព។ អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះត្រូវបានវាយតម្លៃថាមិនអាចធ្វើកើតតាមស្ថានភាពសង្គមឬសេដ្ឋកិច្ច។

២-ប្រសិនបើការណ៍ដែលមិនអាចអនុវត្តកាតព្វកិច្ចនៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ។

-<u>មាត្រា៣៩៦</u> នៃក្រមរដ្ឋប្បវេណី ដីកាបង្គាប់ឲ្យអនុវត្តកាតព្វកិច្ចដោយតុលាការ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាចទាមទារឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបានលើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈ មិនអាចអនុវត្តដោយបង្ខំបាន។ នីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី។

-មាត្រា ៣៩៧ នៃក្រមរដ្ឋប្បវេណី ទំនាក់ទំនងរវាងការទាមទារឲ្យអនុវត្ត កាតព្វកិច្ច និង មធ្យោបាយផ្សេងៗ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចម្ចាស់បំណុលអាចទាមទារ ឲ្យសងការខូចខាត ជំនួសការទាមទារឲ្យអនុវត្តកាតព្វកិច្ចឬជាមួយការទាមទារ ឲ្យអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនមានភាពផ្ទុយគ្នា។

-មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់

១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ទោះបីជា កូន បំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយ ប្រធានសក្តិក៏ដោយក៏កូនបំណុល នោះមិនអាចរួចផុតពីការសងការប្រាក់ក្នុង អំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ។ ការប្រាក់ក្នុង អំឡុងពេលនៃការយឺត យ៉ាវនោះត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់។ បើអត្រា ការប្រាក់ក្នុងកិច្ចសន្យា ខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ នោះត្រូវ គណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា។

២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃ ការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូន បំណុលត្រូវរួចផុតពីការទទួល ខុសត្រូវក្នុងការសងការខូចខាតនោះ។

-មាត្រា៤០៣ នៃក្រមរដ្ឋប្បវេណី ការកំណត់ជាមុននូវចំនួននៃសំណងជាអាទិ៍

១-ម្ចាស់បំណុលនិងកូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេស អំពីល័ក្ខខ័ណ្ឌ និងចំនួនសំណងការខូចខាតបាន។

២-ការសន្យាពិសេសដែលឲ្យកូនបំណុលរួចផុតជាមុនពីការទទួលខុសត្រូវ ក្នុងការមិនអនុវត្តកាតព្វកិច្ចដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងររបស់ខ្លួន មិន មានអានុភាពឡើយ។

៣-ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃ សំណងការខូចខាត តុលាការមិនអាចបន្ថែមឬបន្ថយចំនួននោះបានទេ។ ប៉ុន្តែ

ក្នុងករណីដែលចំនួនទឹកប្រាក់ដែលភាគី ទាំងសងខាងបានកំណត់ជាមុននោះ ច្រើនហួសហេតុពេក ឬតិចហួសហេតុពេក បើប្រៀបធៀបទៅ នឹងការខូចខាត ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃ មាត្រា៤០១ (ទំហំនៃសំណងការខូចខាត) ខាងលើនេះទើបតុលាការអាចបន្ថែមឬបន្ថយនូវប្រាក់សំណងដែលបានកំណត់ជាមុនបាន។

៤-ការកំណត់ជាមុននូវចំនួននៃសំណង មិនរារាំងការទាមទារឲ្យអនុវត្តកាតព្វកិច្ចឬឲ្យរំលាយកិច្ចសន្យាទេ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូច ខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបាន ព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើង ដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះមិនត្រូវចងគូភាគីទេ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង។

-<u>មាត្រា៤០៦</u> **នៃក្រមរដ្ឋប្បវេណី** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល៥(ប្រាំ)ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង។

-<u>មាត្រា៤១៣</u> **នៃក្រមរដ្ឋប្បវេណី** អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារ<u>**បដិទាន**</u>[21]មានអំឡុងពេល៥ (ប្រាំ)ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។

-<u>មាត្រា៤៣៤</u> **នៃក្រមរដ្ឋប្បវេណី** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន។

[21]បដិទានគឺជាការស្តារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ។ ឧ ការបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ឬសងប្រាក់ដែលកូនបំណុលបានបង់ឬបង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងទៅកូនបំណុលវិញឬការបង្វិលសងវិញនូវទ្រព្យមរតកដែលអ្នកគ្មានសិទ្ធិខាងសន្តតិកម្ម បានទទួលជាដើម។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជន បានទេ តតិយជននោះ មិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល។

៣-ម្ចាស់បំណុល និងកូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន។

-<u>មាត្រា៤៣៧</u> **នៃក្រមរដ្ឋប្បវេណី** សិទ្ធិទទួលការសង

១-ការសងនឹងមានសុពលភាពលុះត្រាតែធ្វើចំពោះម្ចាស់បំណុលឬអ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង។

២-បើកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសងកូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀតតាមការទាមទារពីម្ចាស់បំណុលនោះ។ ក្នុងករណីនេះ អ្នកសងអាចទាមទារឲ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះប្រគល់កម្មវត្ថុនៃការសងមកវិញបាន។

-<u>មាត្រា៤៤០</u> **នៃក្រមរដ្ឋប្បវេណី** វិធីសង

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ចនិងតាមគោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់។

-<u>មាត្រា៤៤៣</u> **នៃក្រមរដ្ឋប្បវេណី** ពេលនៃការសង ការសងមុនពេលកំណត់

១-កូនបំណុលត្រូវសងនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា៣៩១(ការយឺតយ៉ាវក្នុងការអនុវត្ត)នៃក្រមនេះ ។

២-កូនបំណុលអាចសងមុនពេលកំណត់បានដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

-<u>មាត្រា៤៤៤</u> **នៃក្រមរដ្ឋប្បវេណី** ម៉ោងសង

កូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា តាមទំនៀមទម្លាប់និងគោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់។

-<u>មាត្រា៤៤៥</u> **នៃក្រមរដ្ឋប្បវេណី** ទីកន្លែងដែលត្រូវសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើងនៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង។ចំពោះកាតព្វកិច្ចក្រៅពីនេះការសងត្រូវធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល។

-<u>មាត្រា៤៧៧</u> នៃក្រមរដ្ឋប្បវេណី ការចេញលិខិតទទួល

អ្នកសងអាចទាមទារឲ្យអ្នកទទួលការសងចេញលិខិតបញ្ជាក់នូវការទទួលការសងនោះបាន។

-<u>មាត្រា៤៨០</u> នៃក្រមរដ្ឋប្បវេណី ការកាត់បំណុលតាមច្បាប់កំណត់

ក្នុងករណីដែលអ្នកសង និងអ្នកទទួលការសងមិនបានធ្វើការជ្រើសរើសដើម្បីកាត់បំណុលនោះទេ ការកាត់បំណុលនោះត្រូវធ្វើឡើងតាមបញ្ញត្តិដូចខាងក្រោមនេះ :

ក-ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងបានមកដល់ និងកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងមិនទាន់មកដល់ត្រូវកាត់កាតព្វកិច្ចដែល ដល់ពេលកំណត់ជាមុនសិន។

ខ-ប្រសិនបើពេលកំណត់ដែលត្រូវសងចំពោះកាតព្វកិច្ចទាំងអស់បានមកដល់ហើយឬមិនទាន់មកដល់នៅឡើយ ត្រូវកាត់កាតព្វកិច្ចដែលមានប្រយោជន៍ក្នុងការសងច្រើនជាងគេសម្រាប់កូនបំណុល។

គ-ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុល ត្រូវកាត់កាតព្វកិច្ច ដែលពេលកំណត់ត្រូវសងបានមកដល់មុនគេឬនឹងមកដល់មុនគេ។

ឃ-ប្រសិនបើកាតព្វកិច្ចទាំងអស់ មានប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និងមានពេលកំណត់ដែលត្រូវសងដូចគ្នាត្រូវកាត់ដោយគិតជាសមាមាត្រតាមចំនួនទឹកប្រាក់នៃកាតព្វកិច្ចនីមួយៗ។

-<u>មាត្រា៤៨២</u> នៃក្រមរដ្ឋប្បវេណី អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល៥(ប្រាំ)ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះឬច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង។

-<u>មាត្រា៤៨៣</u>នៃក្រមរដ្ឋប្បវេណី អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករឬពាណិជ្ជករលក់ទៅឲ្យ

អ្នកដែលមិនមែនជាពាណិជ្ជករនិងថ្លៃសេវាដែលផលិតករឬពាណិជ្ជករផ្តល់ឲ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានអំឡុងពេល២(ពីរ)ឆ្នាំ។

-<u>មាត្រា៤៨២</u>នៃក្រមរដ្ឋប្បវេណី អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរដោយសាលក្រមឬសាលដីកាស្ថាពរឬដោយ ការផ្សះផ្សាតាមផ្លូវតុលាការឬដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជា មានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង៥(ប្រាំ)ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃ ការរំលត់សិទ្ធិនោះត្រូវមានអំឡុងពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ។

២-បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់នៅពេលនៃការចូលជាស្ថាពរ។

-<u>មាត្រា៥១៥</u> នៃក្រមរដ្ឋប្បវេណី និយមន័យនៃការលក់ទិញ

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអ្នកលក់មានករណីយកិច្ច ត្រូវផ្ទេរកម្មសិទ្ធិឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយ អ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។

-<u>មាត្រា៥១៦</u> នៃក្រមរដ្ឋប្បវេណី ការបង្កើតកិច្ចសន្យាលក់ទិញ

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើ<u>**លិខិតយថាភូតឬលិខិតឯកជន**</u>[22] ជាល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន។

[22]- លិខិតយថាភូតគឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀតគឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។

-លិខិតឯកជន គឺជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខាឬស្នាមមេដៃ។

-<u>មាត្រា៤១៨</u> នៃក្រមរដ្ឋប្បវេណី ប្រាក់កក់

បើអ្នកទិញបានបង់ប្រាក់កក់ទៅឲ្យអ្នកលក់ អ្នកទិញអាច<u>រំលាយកិច្ចសន្យាលក់ទិញ ដោយបោះបង់ចោលប្រាក់កក់នោះបាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ ស្មើនឹងពីរដងនៃប្រាក់កក់នេះមកវិញបានដែរ។</u> ប៉ុន្តែ ភាគីមិនអាចរំលាយកិច្ចសន្យាបានឡើយ ក្រោយពេលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យាហើយ។

+**<u>អំពីការបង្កការខូចខាតទ្រព្យសម្បត្តិ</u>**(ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០០៩)

-<u>មាត្រា៤១៨</u>នៃក្រមព្រហ្មទណ្ឌ <u>បទធ្វើឲ្យមានការខូចខាតស្រាល</u> អំពើប្រព្រឹត្តដោយ ចេតនា ដើម្បីបំផ្លិចបំផ្លាញធ្វើឲ្យទ្រុឌទ្រោមឬ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ថ្ងៃទៅ៦(ប្រាំមួយ)ថ្ងៃ និងពិន័យជាប្រាក់ពី១.០០០(មួយពាន់)រៀល ទៅ ១០០.០០០(មួយសែន)រៀល ប្រសិនបើការខូចខាតមានលក្ខណៈស្រាល។

បទប្បញ្ញត្តិនៃមាត្រានេះមិនត្រូវអនុវត្តទៅលើទ្រព្យសម្បត្តិវប្បធម៌សាធារណៈ ឬឯកជនដែលជាផ្នែកនៃបេតិកភណ្ឌជាតិរបស់ព្រះរាជាណាចក្រកម្ពុជាទេ។

-<u>មាត្រា៤១០</u>នៃក្រមព្រហ្មទណ្ឌ <u>បទធ្វើឲ្យខូចខាតដោយចេតនា</u> អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោមឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃ នោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ)ខែ ទៅ ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន) រៀល ទៅ៤.០០០.០០០ (បួនលាន)រៀល លើកលែងតែការខូចខាតមានលក្ខណៈស្រាល។

-<u>មាត្រា៤១១</u> នៃក្រមព្រហ្មទណ្ឌ <u>ស្ថានទម្ងន់ទោស</u> បទល្មើសដែលមានចែងក្នុងមាត្រា៤១០ (បទធ្វើឲ្យខូចខាតដោយចេតនា)នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន)រៀលទៅ ១០.០០០.០០០(ដប់លាន) រៀលនៅក្នុងករណីដូចតទៅ:

១-កាលបើបទល្មើសនេះ បានប្រព្រឹត្តដោយបុគ្គលច្រើនរូបធ្វើសកម្មភាពក្នុងឋានៈជា ចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។

២-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែងជាលំនៅឋាន។

៣-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែង សម្រាប់តម្កល់មូលនិធិតម្លៃទំនិញ ឬសម្ភារៈ។

៤-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឲ្យខូចប្រយោជន៍ដល់សំណង់គ្រឹះស្ថានសាធារណៈឬផ្លូវសាធារណៈ។

៥-កាលបើបទល្មើសនេះបានប្រព្រឹត្តនាំឲ្យខូចប្រយោជន៍ដល់ដំណាំ ឬកសិផល។

៦-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឲ្យខូចបង្គោលព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

+**អំពីការបង្កស្នួសស្នាមតូចតាច**(ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០០៩)

-**មាត្រា២២៨ នៃក្រមព្រហ្មទណ្ឌ** បទហិង្សាស្រាល អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឲ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០(ប្រាំពាន់)រៀល ទៅ១០០.០០០ (មួយសែន)រៀល។

***     ***     ***

## III-**អត្រានុកូលដ្ឋាន**

(*អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០០*)

*មាត្រា២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន* (*លេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០*) *អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួនក្នុងសង្គមជាតិ និងដែលបង្កើតឲ្យជននោះមានសិទ្ធិ និងករណីយកិច្ច។*

*សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃ ពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ក្នុងដែនសមត្ថកិច្ចកំណត់នៃ ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។*

*សំបុត្រអត្រានុកូលដ្ឋាន រួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។*

*មាត្រា៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន*

*ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋាន ជាកាតព្វកិច្ច របស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។*

*មាត្រា៤ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន*

*រាល់ការសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើត និងមរណភាពអ្នករាយការណ៍ និងឬសាក្សី និងឬសាមីខ្លួនត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។*

*ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និង សាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។*

*មាត្រា៧នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន*

*រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ។*

*មន្ត្រីអត្រានុកូលដ្ឋានមិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ។*

*រាល់ការចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី១០ នៃអនុក្រឹត្យនេះ។*

មាត្រា៨ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

មេឃុំ ឬចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំឬសង្កាត់ដែលខ្លួនគ្រប់គ្រង។

នៅពេលដែលមេឃុំ ឬចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរឲ្យជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រម និងរាយការណ៍ជូនអភិបាលស្រុកឬខណ្ឌតាមផ្លូវការ។

ក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមានដោយស្លាប់ ឬដោយបញ្ឈប់ពីមុខតំណែងក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ជូនទៅជំទប់ឬចៅសង្កាត់រងតាមឋានានុក្រម។

មាត្រា៩ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ចៈ

-ទទួលពិនិត្យ កត់ត្រារឿងហេតុសំខាន់ៗទាក់ទង នឹងកំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន។

-ចេញសេចក្តីចម្លងឬសម្រង់នៃអត្រានុកូលដ្ឋានដែលមានក្នុងឆ្នាំមិនទាន់ដាច់

-កែតម្រូវអក្ខរាវិរុទ្ធលើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់តាមលក្ខខណ្ឌមាត្រា១៣ នៃអនុក្រឹត្យនេះ

-អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព

-ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត

-ចុះហត្ថលេខា និងបោះត្រាលើសំបុត្រអត្រានុកូលដ្ឋាន

-<u>កែតម្រូវឬបដិសេធអត្រានុកូលដ្ឋានតាមអំណាចសាលក្រមស្ថាពររបស់តុលាការឬ តាមបទប្បញ្ញត្តិនៃច្បាប់</u>

-ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទឲ្យបានគត់មត់ល្អងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង។

-បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុកឬខណ្ឌផ្ទាល់០១ច្បាប់ និងនៅតុលាការខេត្ត ឬក្រុងសាមី០១ច្បាប់។

-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ ឲ្យបានយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន។

-ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ជារៀងរាល់ខែ និងរាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬសាលាខេត្តសាមី។

-សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់។

## <u>មាត្រា១២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

ក្នុងឃុំឬសង្កាត់នីមួយៗត្រូវមានសៀវភៅអត្រានុកូលដ្ឋានសម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព។

សៀវភៅនេះត្រូវធ្វើជា០២ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និងចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ។ សន្លឹកទី១ និងសន្លឹកចុងក្រោយត្រូវសរសេរជាអក្សរនិងត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុកឬអភិបាលខណ្ឌ។ សន្លឹកទី២ និងសន្លឹកដទៃទៀតអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាលស្រុកឬអភិបាលខណ្ឌគ្រប់សន្លឹក។

## <u>មាត្រា១៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

សៀវភៅអត្រានុកូលដ្ឋានទាំងអស់មិនត្រូវឲ្យមានកោស ធូត លុប សរសេរជ្រៀតថែមឡើយ។ បើមានកោស ធូត លុប ត្រូវទុកពាក្យទាំងនោះឲ្យនៅមើលបានហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថាយល់ព្រមលុបប៉ុន្មានពាក្យនិងយល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និងឬសាក្សី និងឬសាមីខ្លួនចុះហត្ថលេខាឬផ្តិតមេដៃស្តាំទាំងអស់គ្នា។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនឲ្យហែកចោលឡើយ។

មាត្រា១៤នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឲ្យប្រើប្រាស់ចាប់ពីថ្ងៃទី០១ខែមករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ០១ច្បាប់ ទៅសាលាស្រុក ឬខណ្ឌសាមីដើម្បីត្រួតពិនិត្យ និងតម្កល់ទុកនៅទីនោះ និងបញ្ជូន០១ច្បាប់ទៀត ដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬ ក្រុងសាមី ដើម្បីមុខការតាមផ្លូវច្បាប់។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅ ស្ថានទូត ស្ថានអគ្គកុលស៊ុលឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៅខែមករាឆ្នាំបន្ទាប់ មកតម្កល់ទុក០១ច្បាប់នៅក្រសួងមហាផ្ទៃ និង០១ច្បាប់ទៀតមកតម្កល់ទុកនៅក្រសួងយុត្តិធម៌។

**មាត្រា១៥នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន**

មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំទុកដាក់ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និងសំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានឲ្យបានល្អ និងរក្សាការសម្ងាត់របស់បុគ្គលម្នាក់ៗ។

ចំពោះសាលាឃុំឬសង្កាត់ណាដែលមិនធានាសុវត្ថិភាពមន្ត្រីអត្រានុកូលដ្ឋាននៃឃុំឬសង្កាត់នោះត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុកឬខណ្ឌសាមី។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុកឬខណ្ឌទៅតាមបែបបទដូចបានអនុវត្តនៅសាលាឃុំឬសង្កាត់។

**មាត្រា១៧នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន**

បើមានទារកកើត ឪពុកឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំឬសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឲ្យហួស៣០ថ្ងៃ ដោយបញ្ជាក់ឲ្យបានច្បាស់ថាឪពុកនិងម្តាយនៃទារកនោះមានខាន់ស្លាឬឥតខាន់ស្លា។ បើមានខាន់ស្លា ត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកនិងម្តាយទារកនោះ។

បើឪពុកម្ដាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្ដាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹង ឮផ្ទាល់ពីទារកនោះកើតឲ្យទៅចុះសៀវភៅកំណើតឲ្យបានទាន់ពេលកំណត់ដោយយកសំបុត្រអាពាហ៍ពិពាហ៍ឪពុក និងម្ដាយទារកនោះជាប់ទៅជាមួយផង។

មាត្រា២៣នៃអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន

ទារកកើតពីឪពុក ម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុង សៀវភៅកំណើតដែរ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុក ម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានធ្វើយទទួលស្គាល់ដោយជាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថាទារកដែលកើតមកនោះជាកូនរបស់ខ្លួនមន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្ដាយ នោះថាជាឪពុក ម្ដាយរបស់កូននោះ។

ករណីមានតែឪពុកឬមានតែម្ដាយធ្វើយទទួលស្គាល់តែម្នាក់ឯងទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ។

ក្រោយពេលឪពុកឬម្ដាយបានប្ដឹងចុះក្នុងសៀវភៅកំណើតឪពុក ឬម្ដាយណាដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុកឬម្ដាយនោះ អាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន។

កូនឥតខាន់ស្លាដែលឪពុក ម្ដាយបានទទួលស្គាល់ និងទៅជាកូនមានខាន់ស្លាបានប្រសិនបើក្រោយពីកំណើតកូននោះឪពុកម្ដាយរបស់កូននោះបានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន។

មាត្រា២៤ នៃអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន

បើមានទារកកើតហើយ ទុកឲ្យហួសរយៈពេល៣០ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅកំណើតឪពុក ឬម្ដាយ ឬអាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី។

ឪពុក ឬម្ដាយឬអាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដែលខ្លួនរស់នៅដើម្បីចុះសៀវភៅកំណើត។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវធ្វើសេចក្តីណែនាំបន្ថែម។

បញ្ជាក់

យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ (ស.ណ.ន ១៨ ឧសភា ២០០៧) ការចុះសៀវភៅកំណើតត្រូវនាំទៅជាមួយនូវលិខិតស្នាមមួយចំនួន ៖

-លិខិតបញ្ជាក់ទទួលស្គាល់កំណើតរបស់ទារក ចេញដោយមន្ទីរពេទ្យ (ប្រសិនបើទារក កើតនៅមន្ទីរពេទ្យ)ឬ

-លិខិតបញ្ជាក់ទទួលស្គាល់កំណើត ចេញដោយមេភូមិ(បើទារកកើតនៅផ្ទះ)

-ប្រសិនបើមាន ត្រូវយកទៅជាមួយផងដែរ នូវឯកសារមួយចំនួនទៀត ដូចជាសៀវភៅគ្រួសារដែលមានឈ្មោះឪពុកម្តាយរបស់ទារក,សេចក្តីចម្លងសំបុត្រកំណើតរបស់ឪពុកម្តាយ,សេចក្តីសម្លងសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកម្តាយ, អត្តសញ្ញាណប័ណ្ណរបស់ឪពុកម្តាយ។

-ក្នុងករណីឪពុកម្តាយមិនបានទៅ ចុះសៀវភៅកំណើតដោយផ្ទាល់ខ្លួនឯង ហើយពឹងពាក់សាច់ញាតិ ឬអ្នកជិតខាងឲ្យទៅជំនួស ឪពុកម្តាយ ត្រូវធ្វើលិខិតបញ្ជាក់មួយទៀតដោយមានបញ្ជាក់ច្បាស់លាស់ ពីនាមត្រកូល នាមខ្លួន និងថ្ងៃខែឆ្នាំកំណើតរបស់ទារក។

+ក្នុងករណីខកខានមិនបានទៅចុះសំបុត្រកំណើត ក្នុងរយៈពេលកំណត់ ៣០ថ្ងៃ តើត្រូវធ្វើដូចម្តេច?

បើសិនជាកូនកើតមក មិនទៅចុះសំបុត្រកំណើត ទុកឲ្យហួស៣០ថ្ងៃ ការចុះសំបុត្រកំណើត នៅតែអាចធ្វើបាន ប៉ុន្តែត្រូវមានសំណុំបែបបទច្រើនជាងការទៅចុះសំបុត្រកំណើត ក្នុងរយៈពេលកំណត់ ហើយត្រូវមានការបង់ថ្លៃ។ ការសុំចុះសំបុត្រកំណើតហួសពី៣០ថ្ងៃ ក្រោយពីទារកកើត គឺត្រូវធ្វើទៅតាមនីតិវិធីដែលគេហៅថា ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋាន ប៉ុន្តែធ្វើនៅសាលាឃុំសង្កាត់ដែលឪពុកម្តាយរស់នៅដដែលដោយមិនចាំបាច់ត្រូវទៅដល់ស្រុក ខណ្ឌ

ឬក៏ខេត្តក្រុងទេ។ ក្នុងការប្តឹងសុំចុះសំបុត្រកំណើតនេះឪពុក ឬម្តាយរបស់ទារក ត្រូវមានសំណុំឯកសារដូចករណីចុះសំបុត្រកំណើតក្នុងរយៈពេលកំណត់៣០ ថ្ងៃដែរ ប៉ុន្តែត្រូវនាំទៅជាមួយនូវសាក្សី២រូប ដែលជានីតិជនហើយត្រូវបំពេញ ពាក្យប្តឹងសុំចុះសំបុត្រកំណើត។ ពាក្យប្តឹងសុំចុះសំបុត្រកំណើតនេះត្រូវបិទតែមប្រើ ថ្លៃ១ពាន់រៀល សម្រាប់ប្រជាពលរដ្ឋដែលរស់នៅ ខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ។ សម្រាប់អ្នកនៅខេត្តផ្សេងក្រៅពីនេះត្រូវបិទ តែមប្រើថ្លៃ២ពាន់រៀល។ ការទិញតែមប្រើនេះគឺជំនួសឲ្យការបង់លុយ ផ្ទាល់មាន ន័យថាអ្នកសុំមិនតម្រូវឲ្យបង់លុយអ្វីបន្ថែមពីលើនេះទៀតទេ។

និយាយសរុបជារួមមកវិញប្រសិនបើទៅចុះសំបុត្រកំណើតទាន់ពេល គឺ មិនហួសពី៣០ថ្ងៃ ក្រោយពីទារកកើតសំណុំបែបបទមានលក្ខណៈងាយស្រួល ជាងយកសំបុត្រកំណើតត្រូវបេញឲ្យដោយឥតគិតថ្លៃ។ ប៉ុន្តែបើទុកឲ្យហួស៣០ថ្ងៃ បានទៅចុះគឺត្រូវបំពេញសំណុំបែបបទច្រើនជាងហើយត្រូវមានបង់ថ្លៃតាមរយៈ ការទិញតែមប្រើ។

## មាត្រា៨៩នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

ការសុំបញ្ជាក់អត្រានុកូលដ្ឋាន មានចុះសៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្ត ចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យ នេះចូលជាធរមាន។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រ អត្រានុកូលដ្ឋាន កំណើត និងមរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមតុលាការនោះមកសុំ មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។ ឯការបញ្ជាក់អត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ អនុញ្ញាតឲ្យប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ។

-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ លេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦)

ប្រការ១៨ (នៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាល របស់រដ្ឋបាលថ្នាក់ក្រោមជាតិ) ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម៖

-ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ប្រកាសអន្តរក្រសួងលេខ ៦៧៤៤ ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការកែប្រែកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាស អន្តរក្រសួងលេខ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ស្តីពីការផ្តល់សេវា រដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ខែធ្នូ ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **ឃ.រដ្ឋបាលឃុំ សង្កាត់** | | | | | **ចំនួន** |
| **១-ការងារអត្រានុកូលដ្ឋាន** | | | | | |
| ១ | សំបុត្រកំណើត (ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃកើត) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ២ | សំបុត្របញ្ជាក់កំណើត | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៤ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |

| | | | | | |
|---|---|---|---|---|---|
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេសជាមួយពលរដ្ឋខ្មែរ) | ០៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៧ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ០៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៨ | សំបុត្រមរណភាព (ក្នុងរយៈពេល១៥ថ្ងៃ) | ០៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៩ | សំបុត្រមរណភាព (ហួសរយៈពេល១៥ថ្ងៃក្នុងឆ្នាំ) | ០៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | ០៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| **២-ការចេញលិខិតបញ្ជាក់** | | | | | |
| **២.១.ចំពោះឃុំ សង្កាត់ក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារនិងខេត្តឧត្តរមានជ័យ** | | | | | |
| ១ | លិខិតបញ្ជាក់ភាពនៅលីវរមោយឬពោះម៉ាយ | ០៛ | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |
| ២ | លិខិតបញ្ជាក់ទីលំនៅ | ០៛ | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |

<u>មាត្រា១៩នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

បើមានជនណារើសបានទារកដែលគេបោះបង់ចោលត្រូវយកទៅប្រគល់ឲ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំឬសង្កាត់នៃទីកន្លែងដែលរើសទារកនោះ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើកំណត់ហេតុ និងចុះក្នុងសៀវភៅកំណើតដោយរកឈ្មោះដាក់ឲ្យហើយបើក្នុងករណីចាំបាច់មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃខែឆ្នាំកំណើត ទារកដែលរើសបាននោះដោយស្មាន និងឈ្មោះឪពុក ម្តាយដាក់ថាមិនស្គាល់។

បើមានជនណាសុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះទៅមជ្ឈមណ្ឌលសង្គ្រោះទារកឬមជ្ឈមណ្ឌលកុមារកំព្រាដែល នៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រ

កំណើតរបស់ទារកនោះ និងកំណត់ហេតុស្តីអំពីការប្រគល់ទារកនោះជូនមជ្ឈមណ្ឌលសង្គ្រោះទារកឬមជ្ឈមណ្ឌលកុមារកំព្រា។

<u>មាត្រា២៦នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬពីឪពុកជា ពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ឬពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ។ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំឬសង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញឲ្យដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុកហើយចម្លងចេញពីសៀវភៅនូវសំបុត្រកំណើតថ្មីឲ្យយកទៅប្រើប្រាស់។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុលឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញអាចយកសំបុត្រកំណើតដែលប្រគល់ឲ្យនោះមកប្រើប្រាស់ជាផ្លូវការបាន។

<u>មាត្រា២៧នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន</u>

ជនអន្តោប្រវេសន៍និងជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះអាចទៅចុះសៀវភៅកំណើតនៅសាលាឃុំឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅកំណើត នៅស្ថានទូត ស្ថានអគ្គកុងស៊ុលឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូលនិងនាមផ្ទាល់ខ្លួន និងនាមនៃឪពុក ម្តាយរបស់ទារកនោះត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា។

## មាត្រា៩៩ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រពលរដ្ឋ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់មានការឃុបឃិតឬក្លែងបន្លំដោយចេតនាក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋានត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ នឹងប្តឹងទៅតុលាការដើម្បីបដិសេធ និងសុំផ្តន្ទាទោសតាមច្បាប់។

*** *** ***

## IV-គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

( យោងតាមផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ " ភូមិឃុំមានសុវត្ថិភាព " ផែនការណែនាំលេខ០២២ ផ.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ជំនួសឲ្យផែនការណែនាំលេខ០២០ ផ.ក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០)

ភូមិ ឃុំ មានសុវត្ថិភាពគឺភូមិ ឃុំ ដែលមានលក្ខណៈសម្បត្តិ ៩យ៉ាង ដូចខាងក្រោម :

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។

៣-គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ។

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

៦-គ្មានគ្រោះថ្នាក់ចរាចរណ៍។

៧-គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨-មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព

៩-គ្មានការត្រួតពិនិត្យខុសច្បាប់។

### IV-១-វិធានការ និងផែនការសកម្មភាព

**ក-វិធានការ** :

១-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើស លួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន។

២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ ឃុំ សង្កាត់ ដោយអនុវត្តតាមយុទ្ធសាស្ត្រទាំង៥ នៃផែនការជាតិស្តីពី ការ

ត្រួតពិនិត្យគ្រឿងញៀន ផែនការណែនាំលេខ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិ ប្រឆាំងបទល្មើសគ្រឿងញៀន គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើស គ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លេខ០០១/០៦ សណន អ.ជ.ប.គ.ញ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ និងលេខ០០២/០៩ សណន អ.ជ.ប.គ.ញ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០០៩ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ អំពើហឹង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រីនិងកុមារឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហឹង្សា(ឯកសារយោង ផែនការ សកម្មភាពលេខ ០២៣៨.ក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់។

៤.ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ(ឯកសារយោង សារាចរលេខ០៤ ស.រ ចុះថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ០២១ស.ណ.ន ចុះ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០ ផ.ក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង)។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀត ក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន។

៦-អប់រំដល់ជនគ្រប់រូបក្នុងមូលដ្ឋានឲ្យមានការយល់ដឹង និងអនុវត្តបានល្អច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក:

-រដ្ឋបាល ឃុំ សង្កាត់ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាសេនាធិការ យកចិត្តទុកបញ្ជ្រាបការអប់រំដល់ជនគ្រប់រូបនៅក្នុងកម្មវិធីសាសនា កម្មវិធីផ្សេងៗ ក្នុងសង្គម ការអភិវឌ្ឍន៍ វេទិកាសាធារណៈ ដែលរៀបចំឡើងដោយអាជ្ញាធរមានសមត្ថកិច្ចនានារបស់រាជរដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើឲ្យជនគ្រប់រូបកាន់តែយល់ជ្រួតជ្រាប និងអនុវត្តឲ្យកាន់តែល្អត្រឹមត្រូវតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងចេះជួយអប់រំគ្នាទៅវិញទៅមក ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។

-ចំពោះមូលដ្ឋានដែលមានផ្លូវជាតិឆ្លងកាត់ឬតំបន់ដែលមានចរាចរមមាញឹក ត្រូវមានការអប់រំណែនាំដល់ជនគ្រប់រូបមានការប្រុងប្រយ័ត្នពេលឆ្លងកាត់ពេលធ្វើដំណើរតាមដងផ្លូវ។ តំបន់ដែលមានផ្សារ ត្រូវរៀបចំសណ្តាប់ធ្នាប់ឲ្យបានល្អ ត្រូវណែនាំកុំឲ្យមានការដាក់តាំងលក់នៅលើផ្លូវ និងត្រូវរៀបចំឲ្យមានចំណតសម្រាប់មធ្យោបាយ និងយានយន្តគ្រប់ប្រភេទ ដោយមិនត្រូវចតរថយន្តដឹកអ្នកដំណើរ ឬម៉ឺកម៉ូតូ ដែលនាំឲ្យរាំងស្ទះដល់ការធ្វើចរាចរត្រូវណែនាំឲ្យចតឆ្ងាយពីទីប្រជុំជន។

-មូលដ្ឋានដែលមានគ្រឹះស្ថានសិក្សានៅតាមបណ្តោយផ្លូវជាតិ ត្រូវមានអាជ្ញាធរមានសមត្ថកិច្ច(ឬប្រើប្រាស់កម្លាំងប្រជាការពារ) ដើម្បីជួយរៀបចំសណ្តាប់ធ្នាប់ និងការឆ្លងកាត់ផ្លូវរបស់សិស្សានុសិស្សពេលម៉ោងចេញចូលសាលារៀន។

**៧-អប់រំដល់ជនគ្រប់រូបក្នុងមូលដ្ឋានឲ្យយល់ដឹងពីគ្រោះថ្នាក់នៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ហើយចង្អុលបង្ហាញទីតាំងលាក់ ទីតាំងកប់ ដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការដោះស្រាយដើម្បីបញ្ចៀសគ្រោះថ្នាក់បណ្តាលមកពីយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបន្សល់ទុកពីសង្គ្រាម :**

-រដ្ឋបាលឃុំ សង្កាត់ និងនគរបាលប៉ុស្តិ៍រដ្ឋបាល អនុវត្តឲ្យបានល្អតាមផែនការយុទ្ធសាស្ត្ររបស់គណៈបញ្ជាការដឹកនាំបញ្ជាអនុវត្តផែនការយុទ្ធសាស្ត្រកាត់បន្ថយអត្រាគ្រោះថ្នាក់ដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បន្សល់ពីសង្គ្រាមដោយ

យកចិត្តទុកដាក់បញ្ហា៤ ជាសំខាន់ :

- បង្កើនការផ្សព្វផ្សាយអប់រំអំពីច្បាប់ និងផលប៉ះពាល់បណ្តាលមកពីយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដោយចង្អុលបង្ហាញកន្លែងលាក់កប់ដល់សមត្ថកិច្ច
- ប្រមូលព័ត៌មាន ទិន្នន័យព័ត៌មាន ដើម្បីរកឃើញទិន្នន័យពាក់ព័ន្ធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- អនុវត្តវិធានការរដ្ឋបាល ល្បាត ឃ្លាំមើល និងអប់រំអ្នកប្រកបមុខរបរទិញលក់គ្រឿងសំណល់លោហធាតុនិងសិប្បកម្មដែលប្រើប្រាស់កែច្នៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- សង្គ្រោះជនរងគ្រោះបណ្តាលមកពីយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

៨-ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទាន់ពេលគ្រោះមហន្តរាយផ្សេងៗដែលកើតមាននៅក្នុងមូលដ្ឋាន ដូចជា : ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត គ្រោះអគ្គីភ័យ ការពាររន្ទះ រដ្ឋបាលឃុំ សង្កាត់ និងនគរបាលប៉ុស្តិ៍រដ្ឋបាលត្រូវ :

-មានផែនការម្ចាស់ការទុកជាមុនក្នុងការជួយសង្គ្រោះជាបឋម ដើម្បីកាត់បន្ថយហានិភ័យនានា ដែលបណ្តាលមកពីគ្រោះមហន្តរាយខាងលើ ដូចជា អាយុជីវិតមនុស្ស សត្វទ្រព្យសម្បត្តិមុនពេលចុះអន្តរាគមន៍ពីថ្នាក់ជាតិ ថ្នាក់ខេត្ត និងអង្គការសង្គម អង្គការមនុស្សធម៌ ឬអង្គការផ្សេងៗ ទៀត។

-បំផុសចលនាមហាជន ដើម្បីចូលរួមនៅក្នុងការសង្គ្រោះក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយកើតឡើង។

-អប់រំដល់ជនគ្រប់រូបឲ្យមានការយល់ដឹងពីវិធានការបង្ការនានា ដើម្បីជៀសវាងពីការបាត់បង់ជីវិត បាត់បង់ទ្រព្យសម្បត្តិ ជាពិសេសវិធីការពាររន្ទះ ដូចជា កុំស្ថិតនៅទីវាលឬទីខ្ពស់ជាងវត្ថុដទៃ នៅឆ្ងាយពីលោហៈធាតុផ្សេងៗ និងមិនត្រូវប្រើប្រាស់វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ វិទ្យុទាក់ទង កុំស្ថិតនៅក្នុងទឹក ឬក្រោមដើមឈើ ឬបង្គោល ករណី ស្ថិតក្នុងទីវាលត្រូវអង្គុយឱបក្បាលជង្គង់ កុំ

ក្រាបលាតសន្ធឹងខ្លួន ករណីនៅក្នុងទីដែលមានដើមឈើច្រើន ត្រូវជ្រកក្រោមគុម្ពោតឈើ ហើយមិនលិចទឹកជាដើម។

**៩-ចាត់វិធានការលុបបំបាត់ការត្រួតពិនិត្យខុសច្បាប់ តាមដងផ្លូវជាតិ និងដងផ្លូវផ្សេងៗ ក្នុងមូលដ្ឋាន :**

-រដ្ឋបាលឃុំ សង្កាត់ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាសេនាធិការ ត្រូវយកចិត្តទុកដាក់ពិនិត្យតាមដងផ្លូវ ក្នុងមូលដ្ឋានឲ្យបានជាប្រចាំ មិនឲ្យមានការលួចធ្វើសកម្មភាពត្រួតពិនិត្យខុសច្បាប់។

-សហការជាមួយបណ្ដាអង្គភាពឈរជើងក្នុងមូលដ្ឋាន ពិសេសកងកម្លាំងប្រដាប់អាវុធ ដើម្បីអប់រំឲ្យបំពេញតួនាទី ភារកិច្ចត្រឹមត្រូវតាមការកំណត់ មិនរំលោភបំពានលើសិទ្ធិសេរីភាព និងសកម្មភាព ជីវភាពប្រចាំថ្ងៃរបស់ជនគ្រប់រូប។

-អប់រំជនគ្រប់រូបក្នុងមូលដ្ឋាន ចូលរួមចលនាលុបបំបាត់ការត្រួតពិនិត្យខុសច្បាប់ ដោយត្រូវរាយការណ៍បន្ទាន់ជូនសមត្ថកិច្ចនៅពេលបានឃើញមានសកម្មភាពត្រួតពិនិត្យខុសច្បាប់។

***  ***  ***

## V-តួនាទី ភារកិច្ច ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់

(ប្រកាសស្តីពីតួនាទី ភារកិច្ចប៉ុស្តិ៍នគរបាលឃុំ សង្កាត់ លេខ៨៨៣ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១)

-ប្រការ១ នៃប្រកាសស្តីពីតួនាទី ភារកិច្ចប៉ុស្តិ៍នគរបាលឃុំ សង្កាត់ (លេខ៨៨៣ ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១) ប៉ុស្តិ៍នគរបាលរដ្ឋបាល ស្ថិតនៅក្រោមឱវាទផ្ទាល់របស់មេឃុំ ចៅសង្កាត់ និងស្ថិតនៅក្រោមការដឹកនាំជំនាញផ្ទាល់ពីអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មានតួនាទីការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងឃុំ សង្កាត់។

-ប្រការ២ នៃប្រកាសស្តីពីតួនាទី ភារកិច្ចប៉ុស្តិ៍នគរបាលឃុំ សង្កាត់ (លេខ៨៨៣ ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១) ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មានភារកិច្ច :

១-គ្រប់គ្រងការចុះស្ថិតិប្រជាពលរដ្ឋ ចំនួនគ្រួសារ ចំនួនមនុស្សស្នាក់នៅបណ្តោះអាសន្ន ស្នាក់នៅអចិន្ត្រៃយ៍ និងមុខរបរ។

២-ចាត់វិធានការគ្រប់គ្រងហ្មត់ចត់មុខសញ្ញាល្មើសច្បាប់នានាក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។

៣-គ្រប់គ្រងការចុះបញ្ជីស្ថិតិអាវុធជាតិផ្ទុះ ជាតិឆេះ ជាតិពុល កាត់បន្ថយអត្រាគ្រោះថ្នាក់ដោយសារអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ មុខរបរដែលងាយប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងយានជំនិះគ្រប់ប្រភេទតាមការកំណត់របស់ក្រសួង។

៤-ចុះបញ្ជីទីតាំងអង្គភាពកងកម្លាំងប្រដាប់អាវុធ ទីតាំងស្ថានទូត គ្រឹះស្ថានសិក្សា វត្តអារាម រមណីយដ្ឋាន ក្លឹបកំសាន្ត អង្គការជាតិ អន្តរជាតិនានាលំនៅដ្ឋានជនបរទេស ក្រុមហ៊ុន រោងចក្រ សហគ្រាស។

៥-ចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទដែលកើតឡើងក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួនតាមនីតិវិធិច្បាប់ស្រាវជ្រាវរក មនុស្សបាត់ខ្លួន និងការប្រកាសជាសាធារណៈ។

៦-សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ការពារកន្លែងកើតហេតុ ប្រមែប្រមូល ថែរក្សាវត្ថុតាង ធ្វើសេចក្តីរាយការណ៍បឋមជាបន្ទាន់ទៅអធិការដ្ឋាន នគរបាល ក្រុង ស្រុក ខណ្ឌ និងរាយការណ៍ផ្ទាល់ជូនមេឃុំ ចៅសង្កាត់។

៧-ទំនាក់ទំនងសហការជិតស្និទ្ធជាមួយសមត្ថកិច្ចនានា ដែលបោះទីតាំង ក្នុងភូមិសាស្ត្រឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការ សហការផ្តល់ព័ត៌មាននិងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមក ក្នុងការបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើស។

៨-អនុវត្តដីកា សាលក្រម និងសាលដីការបស់តុលាការ។

៩-ល្បាតពួនស្ទាក់ ត្រួតពិនិត្យ តាមចំណុចគោលដៅសំខាន់ៗក្នុង ភូមិសាស្ត្រឃុំ សង្កាត់របស់ខ្លួននិងអនុវត្តការកិច្ចសហគមន៍ សំដៅកៀរគរ កម្លាំងចូលរួមដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

១០-ប្រតិបត្តិម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់កងកម្លាំងនគរបាលជាតិ សំដៅធ្វើឲ្យប្រជាពលរដ្ឋស្រឡាញ់រាប់អាន មានទំនុកចិត្ត និងរាយការណ៍រាល់ ហេតុការណ៍ដែលកើតឡើង។

១១-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់ប៉ុស្តិ៍ជូនមេឃុំ ចៅសង្កាត់ និងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ តាមការកំណត់។

១២-បំពេញភារកិច្ចផ្សេងៗទៀត ដែលអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ប្រគល់ឲ្យ។

-ប្រការ៦ នៃប្រកាសស្តីពីតួនាទី ភារកិច្ចប៉ុស្តិ៍នគរបាលឃុំ សង្កាត់ (លេខ៨៨៣ ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១) អំពីទំនាក់ទំនង:

-ទំនាក់ទំនងរវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលនិងមេឃុំ ចៅសង្កាត់ជាទំនាក់ ទំនង ដឹកនាំ ណែនាំត្រួតពិនិត្យ។

-ទំនាក់ទំនងរវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអធិការនគរបាលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាទំនាក់ទំនងបញ្ជាដឹកនាំការងារជំនាញ។

-ទំនាក់ទំនងរវាងប៉ុស្តិ៍នគរបាលរដ្ឋបាល និងអង្គភាពពាក់ព័ន្ធ ជាទំនាក់ទំនងសហការដើម្បីសម្រេចភារកិច្ច។

-ទំនាក់ទំនងរវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលនិងប្រជាការពារ ជាទំនាក់ទំនងណែនាំ ចាត់ចែងសកម្មភាព។

*** *** ***

## VI-ប្រជាការពារ

(*សេចក្តីណែនាំស្តីពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ (ចលនាប្រជាការពារ) លេខ០១៨ សណន ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១)*

ក្នុងទិសដៅដើម្បីរួមចំណែកពង្រឹកវិធានការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នាថ្ងៃទី២១ ខែឧសភាឆ្នាំ១៩៩៩ ក្រសួងមហាផ្ទៃបានចេញលិខិតលេខ៣៦៤ ស.ជ.ណ ស្តីពីគំរោងការចាត់តាំងចលនាការពារសន្តិសុខៗ នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ ក្រសួងបានចេញលិខិតលេខ០៣៨ ផ.ក ស្តីពីផែនការណែនាំបន្ថែម អំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ(ចលនាប្រជាការពារ) និងចុងក្រោយនេះ លេខាធិការដ្ឋានអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព បានចេញលិខិតជូនដំណឹងលេខ០៦៥ ស.ជ.ណ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំចលនាប្រជាការពារតាមសហគមន៍ភូមិ ឃុំប៉ុន្តែប្រការដែលគួរកត់សំគាល់នោះ គឺឆ្លងតាមរយៈការចាត់តាំងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព នាពេលថ្មីៗនេះ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា: មានមតិជាច្រើនបានលើកឡើងបង្ហាញពីការយល់ដឹងមិនទាន់ឯកភាពគ្នាឬយល់ដឹងផ្សេងពីគ្នាអំពីចលនាប្រជាការពារ ដែលជាហេតុធ្វើឲ្យប្រសិទ្ធិភាពនៃការចាត់តាំងអនុវត្តវិធានការនេះនៅមានកំរិត និងមិនទាន់ឆ្លើយតបបានតាមគោលបំណងសំណូមពរដែលប្រាថ្នាចង់បាននៅឡើយៗ

អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដើម្បីបញ្ជាក់ជាថ្មីដូចតទៅ :

### ១-**អំពីចលនាប្រជាការពារ** :

-ចលនាប្រជាការពារគឺជាសកម្មភាពចូលរួមដោយស្ម័គ្រចិត្តក្នុងស្មារតីភ្ញាក់រលឹករបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដើម្បីរួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមនៅមូលដ្ឋានភូមិ ឃុំ ដែលគាត់រស់នៅ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាននោះៗ

-កម្លាំងប្រជាការពារគឺជាប្រជាពលរដ្ឋ មន្ត្រីរាជការ បុគ្គលិកអង្គការ សមាគមនានា គ្រប់ស្រទាប់ដែលស្ម័គ្រចិត្តចូលរួមធ្វើសកម្មភាពក្នុងចលនា ប្រជាការពារនៅមូលដ្ឋាន។

-កម្លាំងប្រជាការពារ មិនមែនជាអង្គការចាត់តាំងផ្លូវការ ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវឯកភាពឬមានឯកសណ្ឋានណាមួយពិតប្រាកដទេ។ ការចងក្រងកម្លាំងប្រជាការពារ គឺអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃចំនួនប្រជាពលរដ្ឋដែលបានចូលរួម និងលក្ខណៈភូមិសាស្ត្ររបស់ភូមិ ឃុំនីមួយៗ ដែលតម្រូវឲ្យមានការយាមល្បាត ដើម្បីការពារអាយុជីវិត ទ្រព្យសម្បត្តិ និងការបង្ការទប់ស្កាត់បទល្មើស ក៏ដូចជាការរៀបចំសណ្តាប់ធ្នាប់នៅមូលដ្ឋាន។

**២-ភារកិច្ច និងសិទ្ធិរបស់កម្លាំងប្រជាការពារ** :

-ប្រជាការពារមានភារកិច្ចចូលរួមជាមួយកងកម្លាំងនគរបាលឬ កងរាជអាវុធហត្ថ ឬអាជ្ញាធររដ្ឋបាលដែនដី ក្នុងការយាមល្បាតការពារសន្តិសុខ ភូមិ ឃុំ ការពារកន្លែងកំសាន្ត សប្បាយ ពិធីបុណ្យទាន ឬការរៀបចំសណ្តាប់ធ្នាប់ នៅទីសាធារណៈណាមួយតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាននោះ។

-ប្រជាការពារមានភារកិច្ចជួយក្រើនរំឭកដាស់តឿនប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យចេះប្រុងប្រយ័ត្ន ការពារទ្រព្យសម្បត្តិ ផ្ទះសំបែង សត្វពាហនៈ រំលឹកដាស់តឿនរាល់ការធ្វេសប្រហែសនានា ដែលជាអំណោយផល ងាយស្រួលដល់ការប្រព្រឹត្តបទល្មើស និងជួយអប់រំយុវជន យុវនារី ក្នុងមូលដ្ឋានឲ្យអនុវត្តល្អ ជៀសវាងនូវរាល់អំពើអប្បាយមុខផ្សេងៗ ព្រមជាមួយនោះក៏មានភារកិច្ចរាយការណ៍ អំពីមុខសញ្ញា ឬបាតុភាពសង្ស័យទាក់ទិនដល់សន្តិសុខ សណ្តាប់ធ្នាប់ជូន នគរបាល ដើម្បីចាត់វិធានការការពារសុវត្ថិភាពភូមិ ឃុំមានប្រសិទ្ធិភាព។

-ប្រជាការពារមានសិទ្ធិឃាត់ចាប់ជនប្រព្រឹត្តបទល្មើសជាក់ស្តែងនានា ដើម្បីប្រគល់ឲ្យនគរបាលឬកងរាជអាវុធហត្ថឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-ប្រជាការពារពុំមានសិទ្ធិទទួលបាននូវការបំពាក់អាវុធដើម្បីធ្វើសកម្មភាពទេ។

## ៣-ការកសាងកម្លាំងប្រជាការពារ :

ការកសាងកម្លាំងប្រជាការពារ ត្រូវធ្វើឡើងតាមលក្ខការណ៍ស្ម័គ្រចិត្ត ដោយមិនបង្ខំឬមធ្យោបាយណាមួយផ្ទុយពីនេះឡើយ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាជំនួយការ ត្រូវរៀបចំការបំផុសចលនាប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួន សំដៅធ្វើឲ្យមានការយល់ដឹង ដោយភ្ញាក់រលឹកថា ការចូលរួមក្នុងចលនាប្រជាការពារឬការជួយឧបត្ថម្ភដល់ចលនាប្រជាការពារគឺជាការការពារអាយុជីវិតទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារខ្លួន និងខ្លួនឯង ដែលផ្តើមពីនោះ នឹងធ្វើឲ្យចលនានេះមានជាតុសកម្ម ផុលផុស នឹងមានការចូលរួមសស្រាក់សស្រាំ។

-ប្រជាពលរដ្ឋទាំងពីរភេទ គ្រប់វណ្ណៈ ដោយមិនមានការរើសអើង គិតទាំងនិន្នាការនយោបាយ និងសាសនាផង ត្រូវបានទទួលអនុញ្ញាតឲ្យចូលរួមជាកម្លាំងប្រជាការពារ ក្នុងបំណងប្រមែប្រមូលកម្លាំងសរុប វិធានការសរុប ឲ្យបានច្រើនកុះករក្នុងបុព្វហេតុការពារសន្តិសុខមាតុភូមិ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាជំនួយការ ត្រូវមានកម្មវិធីប្រជុំជាមួយកម្លាំងប្រជាការពារ ដើម្បីធ្វើការផ្សព្វផ្សាយជូនដំណឹងអំពីសភាពការណ៍ចាំបាច់នានា គោលការណ៍របស់ឃុំ សង្កាត់ ច្បាប់ទម្លាប់ផ្សេងៗ សភាពការណ៍សន្តិសុខនៅក្នុងភូមិសាស្ត្រ ការប្រឹក្សាយោបល់អំពីវិធានការ ក៏ដូចជាការថែបំប៉នចិត្តសាស្ត្រ ព្រមទាំងត្រូវមានការ ស្នើឡើងដើម្បីសរសើរជូនរង្វាន់ដល់បុគ្គលដែលមានស្នាដៃឆ្នើមក្នុងការចូលរួមចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់ភូមិ ឃុំ ផងដែរ។

## ៤-របៀបធ្វើសកម្មភាពរបស់ប្រជាការពារ :

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាជំនួយការ ត្រូវផ្អែកលើភូមិសាស្ត្រជាក់ស្តែង និងសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់របស់មូលដ្ឋានខ្លួនដើម្បីរៀបចំទីតាំងយាមកាម ឬគំពោង ការដើរល្បាតសំដៅបង្ការទប់ស្កាត់បទល្មើស ក៏ដូចជា សណ្តាប់ធ្នាប់សាធារណៈនៅតាមទីកន្លែងមួយចំនួនដែលចាំបាច់។

-រៀបចំចង្ក្រងកម្លាំងប្រជាការពារជាក្រុម និងរៀបចំបញ្ជី តារាងវេនយាមល្បាតតាមចំនួនជាក់ស្តែង និងចាត់តាំងការយាមល្បាតការពារភូមិ ឃុំ ដោយមាននគរបាលម្នាក់ចូលរួមជាស្នូលបង្អែកសម្រាប់ជួយគាំទ្រខាងផ្នែកអាវុធច្បាប់ ក៏ដូចជាស្មារតី។

ក្នុងករណីពុំមានកម្លាំងនគរបាលចូលរួមជាមួយក្រុមយាមល្បាត ត្រូវរៀបចំឲ្យមានតំណាងអាជ្ញាធរមូលដ្ឋាននិងរៀបចំឲ្យមានមធ្យោបាយសម្រាប់ទាក់ទងជាមួយនគរបាល ដើម្បីជួយធ្វើអន្តរាគមន៍ពេលមានសភាពការណ៍កើតឡើង។

គោលដៅសកម្មភាពរបស់កម្លាំងប្រជាការពារសំខាន់គឺការជួយបង្ការ ទប់ស្កាត់សកម្មភាពបទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន ការជួញដូរមនុស្ស សកម្មភាពក្មេងទំនើង ការលេងល្បែងស៊ីសងខុសច្បាប់ និងជួយរក្សាសណ្តាប់ធ្នាប់សាធារណៈនៅមូលដ្ឋាន។

***      ***      ***

## VII-សៀវភៅស្នាក់នៅ

(ប្រកាសស្តីពីសៀវភៅស្នាក់នៅ លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ខែ១១ ឆ្នាំ១៩៩៧)

-ប្រការ១ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) សៀវភៅស្នាក់នៅ មានគោលដៅចុះឈ្មោះនិងគ្រប់គ្រង មនុស្សដែលកំពុងរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

-ប្រការ២ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) ជនគ្រប់រូបមានកាតព្វកិច្ចចុះឈ្មោះ ក្នុងសៀវភៅស្នាក់នៅ តាមទីកន្លែងដែលខ្លួនស្នាក់នៅជាប់លាប់ក្នុងក្រុមគ្រួសារមួយជាកំណត់។

-ប្រការ៣ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) ជនម្នាក់ៗឬក្រុមគ្រួសារនីមួយៗ មិនអនុញ្ញាតអោយចុះឈ្មោះ ក្នុងសៀវភៅស្នាក់នៅពីរកន្លែងបានឡើយ ទោះមានផ្ទះច្រើនខ្នងឬច្រើនល្វែងក៏ដោយ។

-ប្រការ៦ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) ជនមិនបានត្រូវចុះឈ្មោះក្នុងសៀវភៅស្នាក់គឺ :

-ជនបរទេស មិនមែនអន្តោប្រវេសន៍

-កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិនិង នគរបាលជាតិ ដែលរស់នៅប្រមូលផ្តុំក្នុងបន្ទាយមិនមែនជាគេហដ្ឋាន។ អ្នកទាំងនោះអាចចុះឈ្មោះជាមួយក្រុមគ្រួសាររៀងៗខ្លួនបាន។

-ប្រការ៧ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) ជនគ្រប់រូបអាចសុំផ្លាស់ប្តូរ ទីលំនៅ កែតម្រូវផ្សេងៗ ក្នុងសៀវភៅស្នាក់នៅបាន។ ករណីមានការប្តឹង ប្រកាន់ ក្នុងប្រការអ្វីណាមួយ តាមផ្លូវច្បាប់ សមត្ថកិច្ចនគរបាលមូលដ្ឋានអាចផ្អាកជាបណ្តោះអាសន្ន។

-ប្រការ៨ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៥៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) មេក្រុមគ្រួសារនីមួយៗ ត្រូវជូនដំណឹងទៅសមត្ថកិច្ចនគរបាល មូលដ្ឋានរបស់ខ្លួនអំពី :

-ការកើត ការស្លាប់ ការចាកចេញ ឬចំណូលថ្មីឬការបាត់ខ្លួនរបស់សមាជិក ណាម្នាក់ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។

-ការជូនដំណឹងនេះ យ៉ាងយូររយៈពេល៣ថ្ងៃ។

ប្រការ៩ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៩៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) រាល់ការចុះឈ្មោះស្នាក់នៅ ការគ្រប់គ្រង ការប្រែប្រួល ការផ្លាស់ប្តូរ និងរាល់ការ កែតម្រូវផ្សេងៗ ជាសមត្ថកិច្ចរបស់នគរបាលរដ្ឋបាល។

ប្រការ១០ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៩៦៧ប្រ ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) សៀវភៅស្នាក់នៅ ត្រូវបង្ហាញនៅពេលមានការត្រួតពិនិត្យពីនគរបាលមានសមត្ថកិច្ច សៀវភៅស្នាក់នៅនេះ អាចដកហូតពីក្រុមគ្រួសារឬសាមីជនណាមិនគោរពតាមបទបញ្ញត្តិនៃច្បាប់។

-ដូចជាធ្វើការកោសលុប ការសរសេរត្រួត សរសេរក្លែងក្លាយឬចុះឈ្មោះក្លែងក្លាយ។

-ការឈប់ទទួលស្គាល់សៀវភៅស្នាក់នៅរបស់ក្រុមគ្រួសារឬជនណាមួយ ត្រូវសំរេចដោយសមត្ថកិច្ចនគរបាលថ្នាក់លើ។

ប្រការ១១ នៃប្រកាសស្តីពីសៀវភៅស្នាក់នៅ (លេខ៩៦៧ ប្រ. ក ចុះថ្ងៃទី២១ ខែ១១ ឆ្នាំ១៩៩៧) ជនណាដែលពុំព្រមចុះឈ្មោះខ្លួននិងសមាជិកក្រុមគ្រួសារខ្លួន ក្នុងសៀវភៅស្នាក់នៅរយៈពេលយ៉ាងយូរបីខែ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តតាមមាត្រា៦ នៃអនុក្រឹត្យស្តីពីសៀវភៅស្នាក់នៅ។

*** *** ***

## VIII-បែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ

(ប្រកាសស្តីពីបែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ លេខ០៣៩ ប្រ.ក ចុះថ្ងៃទី១៩ ខែ០១ ឆ្នាំ១៩៩៨)

ប្រការ១ នៃប្រកាសស្តីពីបែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ (លេខ០៣៩ ប្រ.ក ចុះថ្ងៃទី១៩ ខែ០១ ឆ្នាំ១៩៩៨) គ្រប់គ្រួសារដែលមានសញ្ជាតិខ្មែរ មានកាតព្វកិច្ចចុះឈ្មោះសមាជិកគ្រួសារខ្លួនក្នុងសៀវភៅគ្រួសារមួយជាកំណត់នៅទីកន្លែងរបស់ជនបង្គោលមានឪពុក ម្តាយ ដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ២ នៃប្រកាសស្តីពីបែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ (លេខ០៣៩ ប្រ.ក ចុះថ្ងៃទី១៩ ខែ០១ ឆ្នាំ១៩៩៨) សៀវភៅគ្រួសារនេះ ចុះបានតែប្តី ប្រពន្ធ កូនបង្កើត ឬកូនសុំដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ ទោះជាកូនទាំងអស់នោះ រស់នៅទីកន្លែងណាក៏ដោយ។

ប្រការ៣ នៃប្រកាសស្តីពីបែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ (លេខ០៣៩ ប្រ.ក ចុះថ្ងៃទី១៩ ខែ០១ ឆ្នាំ១៩៩៨) គណៈកម្មការត្រួតពិនិត្យ ផ្តល់សៀវភៅគ្រួសារជំហានដំបូងត្រូវដំណើរការចំពោះគ្រួសារដែលមានលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោមនេះ :

១-គ្រួសារប្រជាពលរដ្ឋខ្មែររួមមាន ជនជាតិខ្មែរ ជនជាតិភាគតិច ដែលកំពុងរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

២-កូនជនបរទេសដែលកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងបានរស់នៅជាប់ក្នុងព្រះរាជាណាចក្រកម្ពុជារហូតដល់មានប្តីឬប្រពន្ធ។

៣-កូនដែលកើតពីឪពុកឬម្តាយ មានសញ្ជាតិខ្មែរ និងរស់នៅជាប់ក្នុង ព្រះរាជាណាចក្រកម្ពុជារហូតដល់មានប្តីឬប្រពន្ធ។

៤-គ្រួសារដែលមានប្តីឬប្រពន្ធ ជាជនបរទេស ហើយបានរស់នៅជាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច៣ឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ និងមានព្រះរាជក្រឹត្យសំរេចផ្តល់សញ្ជាតិខ្មែរ។

៥-ជនបរទេសដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការកំណត់នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងបានអនុញ្ញាតអោយចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មឬការទាមទារសញ្ជាតិខ្មែរ តាមការកំណត់នៃច្បាប់ស្តីពីសញ្ជាតិ។

ប្រការ៤ នៃប្រកាសស្តីពីបែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ (លេខ២០៣៩ ប្រ.ក ចុះថ្ងៃទី១៩ ខែ០១ ឆ្នាំ១៩៩៨) ការចុះឈ្មោះក្នុងសៀវភៅគ្រួសារ ការគ្រប់គ្រង ការប្រែប្រួល និងការកែតម្រូវផ្សេងៗជាសមត្ថកិច្ចរបស់ ស្នងការនគរបាលខេត្តក្រុង។

ប្រការ៥ នៃប្រកាសស្តីពីបែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ (លេខ២០៣៩ប្រ.ក ចុះថ្ងៃទី១៩ ខែ០១ ឆ្នាំ១៩៩៨) ជនដែលត្រូវបានលុបឈ្មោះចេញពីសៀវភៅគ្រួសារគឺជនដែលបានទទួលសាលក្រមស្ថាពរអោយដាច់សមត្ថសម្ភាស។

*** *** ***

IX-<u>**នីតិវិធី លក្ខខណ្ឌ នៃការសុំការផ្ដល់និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ**</u> (ប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ លេខ៦៣៧៤ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដា ឆ្នាំ២០១៨)

-<u>ប្រការ១នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ</u> (លេខ៦៣៧៤ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដា ឆ្នាំ២០១៨)

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងលក្ខខណ្ឌនៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសំដៅធានាដល់ការ អនុវត្តន៍កាតព្វកិច្ច សិទ្ធិ និងផលប្រយោជន៍នានារបស់ប្រជាពលរដ្ឋ តាមច្បាប់កំណត់។

-<u>ប្រការ២នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ</u> (លេខ៦៣៧៤ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដា ឆ្នាំ២០១៨)

ក្រសួងមហាផ្ទៃ ប្រគល់សមត្ថកិច្ច ជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដឹកនាំ ជំរុញ ណែនាំ និងសម្របសម្រួលការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូន ប្រជាពលរដ្ឋ។

អភិបាលរាជធានី ខេត្តមានភារកិច្ចទទួលខុសត្រូវដឹកនាំចាត់តាំងអនុវត្តការងារ ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជាអ្នកចុះហត្ថលេខាលើបញ្ជីរាយនាមប្រជាពលរដ្ឋដែលបានបំពេញបែបបទសុំផ្តល់អត្តសញ្ញាណ ប័ណ្ណសញ្ជាតិខ្មែរ។

<u>ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ</u> គិតពីថ្ងៃដែលប្រជាពលរដ្ឋបានបំពេញបែបបទសុំធ្វើ រហូតដល់ថ្ងៃទទួលបានអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ។

-<u>ប្រការ៣នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ</u> (លេខ៦៣៧៤ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដា ឆ្នាំ២០១៨)

<u>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានអាយុពី១៥ឆ្នាំឡើងទៅ ត្រូវទៅធ្វើអត្តសញ្ញាណ ប័ណ្ណសញ្ជាតិខ្មែរនៅស្ថានីយ៍អចិន្ត្រៃយ៍</u> នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬ នៅតាមស្ថានីយ៍ចល័ត នៃឃុំ សង្កាត់ របស់ខ្លួន តាមការជូនដំណឹងរបស់អាជ្ញាធរមាន សមត្ថកិច្ច។

-បង្ហាញមុខដោយផ្ទាល់ជាមួយក្រុមមន្ត្រីនគរបាលជំនាញ និងត្រូវភ្ជាប់មកជាមួយនូវ ៖

- សំបុត្រកំណើតបញ្ជាក់សញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរគំរូចាស់ (ចំពោះអ្នកដែរស្នើសុំអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរ ទុតិយតា) ឬ
- ព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរ ឬ
- សាលក្រមស្តាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាជននោះ កើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬ
- ឯកសារ ឬភស្តុតាងជាផ្លូវការដែលបញ្ជាក់ថា សាមីជនកើតមកពី ឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ និង
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ។

-បំពេញសលាកប័ត្រសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដោយសរសេរ ឲ្យបានត្រឹមត្រូវច្បាស់លាស់ដូចឯកសារសំអាងដែលបានភ្ជាប់មកជាមួយ

-ផ្តិតខ្ទៅដៃ ថតរូប ចុះហត្ថលេខា

-<u>បង់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តាមការកំណត់ នៃ</u>ប្រកាសអន្តរក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-<u>ទទួលស្គាល់បង្កាន់ដៃបង់ប្រាក់ សម្រាប់បង្ហាញអាជ្ញាធរមានសមត្ថកិច្ច នៅពេលទទួលយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។</u>

មិនត្រូវបានអនុញ្ញាតផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំពោះជនទាំងឡាយណាដែល ៖

-កំពុងបំពេញបព្វជិតក្នុងព្រះពុទ្ធសាសនា

-កំពុងអនុវត្តទោសតាមសាលក្រម ឬសាសដីការបស់តុលាការ

-វិកលចរិក

-កំពុងឋិតក្នុងមណ្ឌលអប់រំកែប្រែ

-មានឯកសារផ្លូវការពុំទាន់គ្រប់គ្រាន់ថាខ្លួនមានសញ្ជាតិខ្មែរ។

-ប្រការ៤នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

ការធ្វើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖

-ប្រធានភូមិ មន្រ្តីប៉ុស្តិ៍នគរបាលរដ្ឋបាល ស្មៀនឃុំ សង្កាត់ សហការធ្វើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលមានអាយុពី១៥ឆ្នាំឡើង ដោយពិនិត្យផ្ទៀងផ្ទាត់តាមសំបុត្រកំណើត សៀវភៅស្នាក់នៅ "ក២ ឬសៀវភៅគ្រួសារក៤" ឬឯកសារភស្តុតាងបញ្ជាក់សញ្ជាតិខ្មែរផ្សេងទៀតដូចមានចែងក្នុង ប្រការ៣នៃប្រកាសនេះ

-នាយប៉ុស្តិ៍នគរបាលរដ្ឋបាល មេឃុំ ចៅសង្កាត់ អធិការនគរបាលក្រុង ស្រុក ខណ្ឌ និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងចុះហត្ថលេខាទទួលខុសត្រូវ លើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

-ប្រការ៥នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

ការបំពេញបែបបទប្រមូល និងបញ្ចូលទិន្នន័យ សម្រាប់ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ៖

-អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌត្រូវ ៖

- ចាត់មន្រ្តីនគរបាលជំនាញបំពេញបែបបទប្រមូលទិន្នន័យនៅតាមស្ថានីយ៍អចិន្រ្តៃយ៍នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬ ស្ថានីយ៍ចល័តនៅតាមឃុំ សង្កាត់
- បញ្ជូនទិន្នន័យទៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីធ្វើ បញ្ជីរាយនាមប្រជាពលរដ្ឋដែលបានបំពេញបែបបទសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររួចហើយសុំការពិនិត្យសម្រេចពីអភិបាលរាជធានី ខេត្ត

-ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវបញ្ជូនបញ្ជីរាយនាមប្រជាពលរដ្ឋ ដែលបានពិនិត្យសម្រេចរួចដោយអភិបាលរាជធានី

ខេត្ត និងទិន្នន័យទៅមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរបស់ក្រសួងមហាផ្ទៃសម្រាប់ ធ្វើការបោះពុម្ពអត្តសញ្ញាណប័ណ្ណ

-ក្នុងករណីចាំបាច់ តាមសំណើរបស់ក្រសួង ស្ថាប័ននានា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មអាចចាត់មន្ត្រីនគរបាលជំនាញ៖

- បំពេញបែបបទប្រមូលទិន្នន័យសម្រាប់ការផ្តល់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិក ដែលប្រមូលផ្តុំនៅទីកន្លែងបំពេញការងារ
- ធ្វើបញ្ជីឈ្មោះមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិកដែលបានបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែររួចហើយ ដើម្បីសុំការពិនិត្យសម្រេចពីអគ្គនាយកនៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- ធ្វើការបោះពុម្ពអត្តសញ្ញាណប័ណ្ណ និងប្រគល់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរដែលបោះពុម្ពរួចជូនទៅសាមីក្រសួង ស្ថាប័នដែលស្នើសុំដោយមានកំណត់ហេតុប្រគល់ទទួលត្រឹមត្រូវច្បាស់លាស់
- បញ្ជូនសំណុំឯកសារនិងទិន្នន័យ ដែលបានផ្តល់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែររួច ទៅស្នងការដ្ឋាននគរបាលរាជធានីខេត្ត ដែលជា ទីលំនៅអចិន្ត្រៃយ៍របស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិក ដើម្បីបានជ្រាប និងបន្តការគ្រប់គ្រង។

-<u>ប្រការ៦នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ</u> (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

ប្រជាពលរដ្ឋពេលទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីកន្លែងកំណើត អាសយដ្ឋាន ឬព័ត៌មានផ្សេងៗទៀត។

ក្នុងករណីពិនិត្យឃើញថា មានព័ត៌មានខុសពីព័ត៌មាននៅក្នុងឯកសារឬកស្តុតាង ផ្សេងៗដែលសាមីខ្លួនបានផ្តល់ជូនអាជ្ញាធរមានសមត្ថកិច្ច នៅពេលបំពេញបែប បទស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណ សាមីខ្លួនត្រូវតវ៉ាទៅនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌនៃលំនៅដ្ឋានរបស់ខ្លួន ដោយភ្ជាប់ជាមួយ អត្តសញ្ញាណប័ណ្ណដែលមានព័ត៌មានខុស និងឯកសារកស្តុតាងផ្សេងៗដែលផ្តល់ ជូនអាជ្ញាធរមានសមត្ថកិច្ច នៅពេលបំពេញបែបបទស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណ។

បន្ទាប់ពីទទួលការតវ៉ាពីប្រជាពលរដ្ឋ៖

-នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអធិការ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារដែលពាក់ព័ន្ធនានា រួចរៀបចំបញ្ជូនសំណើសុំ កែតម្រូវ ដោយភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណដែលខុស និងឯកសារដែលពាក់ព័ន្ធទៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

-ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវពិនិត្យផ្ទៀតផ្ទាត់ និងរៀបចំសំណុំឯកសារបញ្ជូនទៅអគ្គិបាលរាជធានី ខេត្ត ស្នើសុំការពិនិត្យសម្រេច រួចបញ្ជូនទៅអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យសម្រេចកែតម្រូវទិន្នន័យ និងបោះពុម្ពអត្តសញ្ញាណប័ណ្ណថ្មី។

ការកែតម្រូវព័ត៌មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលការតវ៉ាសុំកែតម្រូវរបស់ប្រជាពលរដ្ឋនៅអធិការដ្ឋាន នគរបាលក្រុង ស្រុក ខណ្ឌ រហូតដល់ថ្ងៃប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែល បានកែតម្រូវរួចជូនប្រជាពលរដ្ឋ។

-ប្រការ៨នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

ត្រូវបានដកហូតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាបណ្តោះអាសន្ន និងឬជាស្ថាពរក្នុងករណី៖

-ជនដែលមានសាលក្រម ឬសាលដីការបស់តុលាការបង្គាប់ឲ្យដកហូត

-ជនគ្មានសញ្ជាតិខ្មែរ តែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

-ប្រការ៩នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

ក្នុងករណីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបានបាត់ សាមីខ្លួន ត្រូវប្តឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅឃុំ សង្កាត់ ដែលកើតឡើងការបាត់ មិនលើស២៤ម៉ោងបន្ទាប់ពីដឹងថាបាត់។ ប្រសិនបើការបាត់កើតឡើងក្រៅឃុំ សង្កាត់របស់ខ្លួន សាមីខ្លួនត្រូវជូនដំណឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅឃុំ សង្កាត់ ដែលខ្លួនកំពុងរស់នៅ មិនលើស៤៨ម៉ោង បន្ទាប់ពីវិលត្រឡប់ដល់លំនៅដ្ឋានវិញ។

ករណីដែលសមត្ថកិច្ចពិនិត្យឃើញថា ជននោះពិតជាបាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រាកដមែន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ "ទុតិយតា" និងត្រូវបានផ្តល់ជូន ក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលបណ្តឹង ឬដំណឹង និងសាមីខ្លួនបានបំពេញសំណុំលិខិតគ្រប់គ្រាន់។

ក្នុងករណីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបានខូច ឬអស់សុពលភាព សាមីខ្លួនត្រូវបំពេញបែបបទស្នើសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ "ទុតិយតា" នៅស្ថានីយ៍អចិន្ត្រៃយ៍នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬនៅតាមស្ថានីយ៍ចល័តនៃឃុំ សង្កាត់ របស់ខ្លួនរស់នៅដោយភ្ជាប់មកជាមួយសន្លឹកអត្តសញ្ញាណប័ណ្ណ ដែលខូច ឬអស់សុពលភាព។

-ប្រការ១០នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព១០ឆ្នាំ។ មុនពេលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាពរយៈពេល៩០ថ្ងៃ សាមីខ្លួនត្រូវសុំធ្វើសាជាថ្មីឡើងវិញ "ទុតិយតា" នីតិវិធីនៃការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវបំពេញសំណុំលិខិតដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ។

-ប្រការ១១នៃប្រកាសស្តីពីនីតិវិធី លក្ខខណ្ឌ នៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (លេខ៦៣៧៥ប្រ.ក ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១៥)

ត្រូវទទួលទណ្ឌកម្មរដ្ឋបាលឬ/និងទទួលទោសតាមច្បាប់ជាធរមានចំពោះជនណាដែលៈ

-រាយការណ៍ចុះឈ្មោះផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទ

សុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-គ្មានសញ្ជាតិខ្មែរ ប៉ុន្តែកាន់កាប់ ឬប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-ក្លែង កោស លុប ឲ្យអ្នកដទៃខ្ចី ឬសរសេរត្រួតក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-មានចេតនាជួយសម្រួលសំណុំបែបបទ ឬសម្រេចផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឲ្យជនដែលគ្មានសញ្ជាតិខ្មែរ។

***  ***  ***

## X-ការផ្តល់សេវារដ្ឋបាល

(ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ លេខ១៤៤ ១៤ ប្រក ចុះថ្ងៃទី៣០ខែធ្នូ ឆ្នាំ២០១៦)

ប្រការ៨នៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម ៖

-ប្រកាសអន្តរក្រសួងលេខ២០៨៧ ប្រក ចុះថ្ងៃទី១៥ ខែតុលាឆ្នាំ២០១០ ស្តីពីការកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-ប្រកាសអន្តរក្រសួងលេខ ៣៦៦៦ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

-ប្រកាសអន្តរក្រសួងលេខ ៨០២៨ ប្រក ចុះថ្ងៃទី២៨ ខែតុលាឆ្នាំ២០១៦ ស្តីពីការកែសម្រួលកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ៣៦៦៦ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ១៤៤១៤ ប្រក ចុះថ្ងៃទី៣០ខែធ្នូ ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ខ.កិច្ចការអត្រានុកូលដ្ឋាន | | | | | |
| ៤ | ការស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយប្រជាពលរដ្ឋខ្មែរ | 0៛ | ២៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| គ.កិច្ចការស្ថិតិប្រជាពលរដ្ឋ | | | | | |
| ៥ | ការផ្តល់សៀវភៅស្នាក់នៅ | 0៛ | ១០ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |

| | | | | | |
|---|---|---|---|---|---|
| ៦ | ទុតិយតា ឬតតិយតាសៀវភៅស្នាក់នៅ | ០៛ | ១០ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៧ | ការស្នើសុំបន្ថែមឬបន្ថយសមាជិកគ្រួសារក្នុងសៀវភៅស្នាក់នៅ | ០៛ | ១០ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៨ | ការផ្តល់សៀវភៅគ្រួសារ | ០៛ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៩ | ទុតិយតា ឬតតិយតាសៀវភៅគ្រួសារ | ០៛ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ១០ | ការស្នើសុំបន្ថែម ឬបន្ថយសមាជិកគ្រួសារក្នុងសៀវភៅគ្រួសារ | ០៛ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| **ឃ.កិច្ចការអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** | | | | | |
| ១១ | ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ០៛ | ៣០ថ្ងៃ | ១០ឆ្នាំ | ១សន្លឹក |
| ១២ | ទុតិយតា ឬតតិយតា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ០៛ | ៣០ថ្ងៃ | ១០ឆ្នាំ | ១សន្លឹក |

**-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦**)

ប្រការ១៨ (នៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម៖

-ប្រកាសអន្តរក្រសួងលេខ២៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ប្រកាសអន្តរក្រសួងលេខ ៦៧៤៤ ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ស្តីពីការកែប្រែកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាស អន្តរក្រសួងលេខ២៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ស្តីពីការផ្តល់សេវា រដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ខែធ្នូ ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| -ខ.រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយ<br>-គ.រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានការិយាល័យច្រកចេញចូលតែមួយ | | | | | |
| ១.ការងារទីភ្នាក់ងារនុក្កូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង) | | | | | |
| ២២ | អត្តសញ្ញាណប័ណ្ណ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ២៣ | សៀវភៅស្នាក់នៅ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៣.ការងារអត្រានុកូលដ្ឋាន | | | | | |
| ១ | សេចក្តីចម្លងសំបុត្រកំណើតឬសំបុត្របញ្ជាក់កំណើត | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ២ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៣ | សេចក្តីចម្លងសំបុត្រមរណភាពឬសំបុត្របញ្ជាក់មរណភាព | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ឃ.រដ្ឋបាលឃុំ សង្កាត់ | | | | | ចំនួន |
| ១-ការងារអត្រានុកូលដ្ឋាន | | | | | |
| ១ | សំបុត្រកំណើត (ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃកើត) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ២ | សំបុត្របញ្ជាក់កំណើត | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |

| | | | | | |
|---|---|---|---|---|---|
| ៣ | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៤ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេសជាមួយពលរដ្ឋខ្មែរ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៧ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៨ | សំបុត្រមរណភាព (ក្នុងរយៈពេល១៥ថ្ងៃ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ៩ | សំបុត្រមរណភាព (ហួសរយៈពេល១៥ថ្ងៃក្នុងឆ្នាំ) | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | 0៛ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | ១សន្លឹក |
| ២-ការចេញលិខិតបញ្ជាក់ | | | | | |
| ២.១.ចំពោះឃុំ សង្កាត់ ក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ | | | | | |
| ១ | លិខិតបញ្ជាក់ភាពនៅលីវមេម៉ាយឬពោះម៉ាយ | 0៛ | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |
| ២ | លិខិតបញ្ជាក់ទីលំនៅ | 0៛ | ៣ថ្ងៃ | ៣ខែ | ១សន្លឹក |

# ព្រឹទ្ធសភា នីតិកាលទី៣

# គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

(ហៅកាត់ថា គណៈកម្មការទី៦ ព្រឹទ្ធសភា)

## I.គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

១-ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការ

២-ឯកឧត្តម **ជា សុន** អនុប្រធានគណៈកម្មការ

៣-ឯកឧត្តម **ថុង ចន់** លេខាធិការគណៈកម្មការ

៤-ឯកឧត្តម **ហេង ប៊ូរ៉ា** សមាជិកគណៈកម្មការ

៥-ឯកឧត្តម **ជុំ វង** សមាជិកគណៈកម្មការ

## II.ជំនួយការឯកទេសជាន់ខ្ពស់អមប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា

១-លោក **គង់ សារិទ្ធ** ជំនួយការឯកទេសជាន់ខ្ពស់អមប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភា

## III.លេខាធិការដ្ឋានអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

១-លោក **នៃ នីន** ប្រធានលេខាធិការដ្ឋាន

២-លោក **អ៊ុក រិទ្ធី** អនុប្រធានលេខាធិការដ្ឋាន

៣-លោកស្រី **ងី តេង** អនុប្រធានលេខាធិការដ្ឋាន

៤-លោក **លី វិសាល** មន្ត្រីលេខាធិការដ្ឋាន

៥-លោក **សុខ សម្ផស្ស** មន្ត្រីលេខាធិការដ្ឋាន

៦-លោកស្រី **ងី សុភា** មន្ត្រីលេខាធិការដ្ឋាន

៧-លោកស្រី **យស់ ច័ន្ទរដ្ឋា** មន្ត្រីលេខាធិការដ្ឋាន